


#SEE ALL THE PEOPLE





# ការអភិវឌ្ឍន៍ ប្រព័ន្ធបង្កើតសិស្ស ដោយចេតនា៖ សេចក្ដីណែនាំសំរាប់ក្រុមជំនុំ





Junius B. Dotson





# ការអភិវឌ្ឍន៍ប្រព័ន្ធបង្កើតសិស្សដោយចេតនា៖ សេចក្តីណែនាំសំរាប់ក្រុមជំនុ

Junius B. Dotson

Copyright 2017 Discipleship Ministries.

ខគម្ពីរយកចេញពី the New Revised Standard Version of the Bible, The New Interpreter's Study Bible. Abingdon Press, 2003.

គ្រប់ទាំងសំរង់ចេញពី The Book of Discipline of The United Methodist Church - 2016 គឺរក្សាសិទ្ធិ ឆ្នាំ 2016 ដោយ The United Methodist Publishing House. ប្រើដោយមានការអនុញ្ញាតិ.

បើអ្នកចង់រៀនពីធនធានរបស់ Discipleship Ministries, សូមចូលទៅកាន់ UMCdiscipleship.org.

ធនធាននេះត្រូវបានគាំទ្រដោយ The World Service Fund of The United Methodist Church.

1908 Grand Avenue
Nashville, TN 37212
UMCdiscipleship.org
877.899.2780

# មាតិកា


សេចក្ដីផ្ដើម ..... 4

ការបង្កើតសិស្សផ្ទាល់ខ្លួននិងជាក្រុម ..... 6

ត្រូវការភាពច្បាស់លាស់៖ អ្វី យ៉ាងម៉េច ហេតុអ្វី ..... 10

- អ្វី ..... 10
- អ្វី & យ៉ាងម៉េច៖ សំនួរច្រំដែលពីរ ..... 11
- ហេតុអ្វី ..... 12

ការយល់&ការរកឃើញពី «ហេតុអ្វី» នៃការបង្កើតសិស្ស ..... 16

- ជម្រៅហេតុអ្វី ..... 17
- ការរកឃើញពីហេតុអ្វីរបស់យើង ..... 19

ប្រព័ន្ធនៃការបង្កើតសិស្សដោយចេតនា ..... 22

- ប្រព័ន្ធហេតុអ្វី ..... 22
- បរិបទ ភាសា និងកម្មសិទ្ធិ ..... 23
- តើសិស្សជាអ្វី ..... 23
- អត្តចរិកនៃប្រព័ន្ធនៃការបង្កើតសិស្សដោយចេតនា ..... 24

គំនិតសំរាប់បង្កើតប្រព័ន្ធនៃការបង្កើតសិស្សដោយចេតនារបស់អ្នក ..... 28

- វិធីតាមបែបលោកវេស្លី ..... 29
- ការបង្កើតសិស្សផ្ទាល់ខ្លួន & ការដឹកនាំ ..... 30

ការឃើញ&ការឈោងចាប់មនុស្សគ្រប់គ្នា ..... 32

- ហោណ័ងមុខផ្ទះធំ ..... 32
- អ្វីទាំងអស់គឺទាក់ទងនិងទំនាក់ទំនង ..... 33

ការបង្កើតសិស្សដោយចេតនាក្នុងនិកាយទាំងមូល ..... 36

ការសិក្សាបន្ថែម ..... 48

អំពីអ្នកនិពន្ធ ..... 50

ព្រះយេស៊ូវ ទ្រង់ក៏យាងទៅដល់គ្រប់ក្រុងគ្រប់ភូមិ ព្រមទាំងបង្រៀនក្នុងសាលាប្រជុំទាំងប៉ុន្មាន ហើយប្រកាសប្រាប់ដំណឹងល្អពីនគរ ទ្រង់ក៏ប្រោសអស់ទាំងជំងឺរោគា និងជរាពិការ ក្នុងពួកបណ្តាជនឲ្យបានជា  កាលទ្រង់ឃើញហ្វូងមនុស្សហើយ នោះទ្រង់មានព្រះហឫទ័យក្តួលអាណិតដល់គេ ដ្បិតគេល្វើយ ហើយខ្ចាត់ខ្ចាយ ដូចហ្វូងចៀម ដែលឥតអ្នកគង្វាល បានជាទ្រង់មានព្រះបន្ទូលទៅពួកសិស្សថា ចំរូតធំណាស់ តែមានអ្នកច្រូតតិចទេ ដូច្នេះ ចូរសូមអង្វរដល់ព្រះអម្ចាស់នៃចំរូត ឲ្យទ្រង់ចាត់អ្នកច្រូតមកក្នុងចំរូតទ្រង់។

– ម៉ាថាយ ៩៖៣៥-៣៨

# សេចក្តីផ្តើម

ចំរូតធំណាស់ តែមានអ្នកច្រូតតិចទេ។ ថ្ងៃនេះ មិនខុសពីសម័យរបស់ព្រះយេស៊ូវ មនុស្សនៅតែមានសេចក្តីត្រូវការផ្នែកព្រលឹងវិញ្ញាណ និងស្វែងរកអត្ថន័យសំរាប់ជីវិតរបស់គេ។ អ្នកខ្លះ ដូចក្នុងបទគម្ពីរម៉ាថាយ ត្រូវបានគេរុកគួន និងមិនមានអ្វីជួយបាន។ អ្នកខ្លះកំពុងស្វែងរក ដំណឹងល្អ។ អ្នកខ្លះត្រូវការការប្រោសឲ្យជា។ ព្រះយេស៊ូវបានក្នុងភូមិ ក្រុង ហើយមានព្រះទ័យក្តួលអាណិតដល់គេ... យើងដែលជាសិស្សរបស់ទ្រង់គួរធ្វើអញ្ចឹងដែរ។

ខ្ញុំចាំកំណាព្យដែលរៀនពីថ្នាក់ថ្ងៃអាទិត្យ កាលពីខ្ញុំនៅក្មេង...

**នេះជាព្រះវិហារ នេះជាកំពូលស្រួចព្រះវិហារ បើកទ្វារ និងមើលមនុស្សគ្រប់គ្នា។**

ជាអកុសល ក្រុមជំនុំសព្វថ្ងៃជាច្រើនសរសេរកំណាព្យនេះឡើងវិញ «បើកទ្វារ តើឯណាមនុស្ស?» ទោះជាមានឧទាហរណ៍នៃភូមិ និងទីក្រុងខ្លះ ដែលការងារ និងមនុស្សបានចេញអស់ ភូមិនិងទីក្រុងភាគច្រើនរាយការណ៍ថា ចំនួនប្រជាជនកើនឡើងរាល់ឆ្នាំ។ បញ្ហាគឺមិនមែនដោយសារខ្វះមនុស្សទេ។ បញ្ហាគឺជាការដែលយើងគ្មានសមត្ថភាពឈោងចាប់ពួកគេ។ យើងភ្លេចថា ហេតុអ្វីបានជាក្នុងនាមជាសិស្ស យើងត្រូវបានត្រាស់ហៅឲ្យឈោងចាប់មនុស្ស។

មានរឿងមួយដែលអ្នកមានចិត្តល្អម្នាក់ជួលមនុស្សក្នុងសម័យសេដ្ឋកិច្ចធ្លាក់ចុះឲ្យធ្វើផ្លូវថ្នល់។ ទោះជាគាត់មានបំណងល្អ តែអ្នកមានម្នាក់នេះជួលមនុស្សឲ្យធ្វើការដែលគ្មានន័យដោយសារផ្លូវនោះគ្មានទីដៅពិតប្រាកដទេ។ ពេលដែលអ្នកធ្វើការចាប់ផ្តើមយល់ថា ការងាររបស់ពួកគេ គ្មានគោលបំណងច្បាស់លាស់ នោះចំណង់ក្នុងការធ្វើការនេះ ក៏រំសាយអស់ទៅ។

ពេលយើងនិយាយអំពីការបង្កើតសិស្សដោយគោលបំណង យើងត្រូវដឹងពីគោលដៅច្បាស់ លាស់ ហើយយើងត្រូវដឹងពីហេតុផល ពីក្រោយបេសកកម្មនៃការបង្កើតសិស្ស។ ក្នុងសៀវភៅនេះ យើងនឹងហៅ «ហេតុអ្វី» នៃការបង្កើតសិស្ស។ បើសិនជាយើងពិតជាចង់ធ្វើផ្លូវនៃការបង្កើតសិស្ស យើងត្រូវយល់ថាហេតុអ្វីបានជាយើងសង់វា វាបត់បែនដល់ណា ហើយវាទៅដល់ណា។ សេចក្ដីត្រូវការវាធំធេងណាស់ ហើយចលនានេះវាសំខាន់ណាស់ ដែលយើងមិនអាចសង់ផ្លូវដោយគ្មានគោលដៅបានទេ។

រាប់ឆ្នាំមកនេះ ជាមួយនិងគោលបំណងដែលយើងមាន យើងបានព្យាយាមបង្កើតសិស្សដោយភ្ជាប់ជាមួយកម្មវិធីថ្វាយបង្គំ ប្រមូលទិន្នន័យយ៉ាងច្រើន តាមដានស្ថិតិសង្គមបង្កើតសិស្សជាយុទ្ធសាស្ត្រជាក់លាក់មួយបង្កើតក្រុមបដិសណ្ឋារកិច្ចនិងផ្សារផ្ជាប់ជាមួយផ្នែកផ្សេងទៀត នៃជីវិត ក្រុមជំនុំ។ ចំនុចទាំងនេះសំខាន់ ហើយចាំបាច់សំរាប់ក្រុមជំនុំរឹងមាំ តែវាក៏អាចរំខានយើង ហើយនាំយើងឲ្យជឿថា យើងអាចផ្សារភ្ជាប់ ឬធ្វើកម្មវិធីដែលទាក់ទងនិងភាពរឹងមាំ ក្នុងក្រុមជំនុំរបស់យើង។

យូរពេកហើយ ដែលក្រុមជំនុំយូណៃធីតមេថូឌីស្ទ បានស្វែងរកវិធីជួសជុលងាយៗដើម្បីដឹកនាំ ការប្រឹងប្រែងរបស់យើង ហើយវាមិនបានផលទេ។ យើងបាត់ការផ្ដោតអារម្មណ៍ យើងភ្លេចមូលហេតុដែលយើងឆ្លើយថា «បាទ/ចាស៎» ចំពោះព្រះយេស៊ូវ ហើយយើងខ្លួនឯងបានឈប់ លូតលាស់ក្នុងនាមជាសិស្ស។ យើងភ្លេចថា ផ្នែកនៃភាពជាសិស្ស គឺជាដំណើរពេញមួយជីវិត នៃការរីកលូតលាស់ និងពេញវ័យ។ ខ្ញុំជឿថា ការផ្ដោតជាថ្មីចំពោះការបង្កើតសិស្ស គឺជាការបណ្ដាក់ទុននៃពេលវេលា ថវិការ និងធនធាន របស់យើង។ យើងត្រូវប្ដូរការផ្ដោតអារម្មណ៍របស់យើងចេញពីការ «ជួសជុល» ក្រុមជំនុំ ឲ្យជាការបង្កើតសិស្ស។ ខ្ញុំចូលចិត្តសំរង់ចេញពីអ្នកនិពន្ធ ឈ្មោះ Mike Breen ដែលបាននិយាយថា

**«បើអ្នកព្យាយាមសង់ក្រុមជំនុំ នោះអ្នកកម្រទទួលបានសិស្សណាស់។ តែបើអ្នកបង្កើតសិស្ស នោះអ្នកនឹងទទួលបានក្រុមជំនុំ។»**[1]

ក្នុងស្មារតីនេះហើយ ដែលយើងផ្ដោតលើការត្រាស់ហៅនៃការបង្កើតសិស្សដោយចេតនា ជាមួយនិងការចង់ជួយឲ្យមានភាពច្បាស់លាស់និងបេសកកម្មរបស់ក្រុមជំនុំដើម្បីផ្ដល់គោលការណ៍ល្អៗសំរាប់ការបង្កើតសិស្សដោយចេតនានិងបំផុសឲ្យមានចិត្តឆេះឆួលក្នុងការបង្កើតសិស្ស នៅក្នុងនិកាយយើងទាំងមូល។ ខ្ញុំអធិស្ឋានឲ្យក្រុមជំនុំទាំងអស់ ត្រូវតែផ្ដោតលើការបង្កើតសិស្ស ហើយចលនាបង្កើតសិស្សសាយភាយក្នុងនិកាយយើងទាំងមូលម្ដងទៀត។ខ្ញុំសង្ឃឹមថាអ្នកនឹងប្រើកូនសៀវភៅនេះ សំរាប់លើកទឹកចិត្តក្រុមជំនុំដទៃទៀត ឲ្យគេធ្វើបេសកកម្មនៃការបង្កើតសិស្សសំរាប់ បំផ្លាស់បំប្រែពិភពលោក ហើយយើងផ្ដោតការទាំងអស់ដែលយើងធ្វើក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ។

---

[1] *Building a Discipleship Culture.* Mike Breen. 3dm Publishing, 2014.

ខ្ញុំសូមអញ្ជើញអ្នកជាផ្លូវការ អោយចូលរួមក្នុងចលនានេះជាមួយគ្នា៖ដូច្នេះ ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន ហើយខំថែរក្សាហ្វូងសិស្ស ដែលព្រះវិញ្ញាណបរិសុទ្ធបានតាំងអ្នករាល់គ្នា ឲ្យធ្វើជាអ្នកគង្វាលដល់គេ ដើម្បីឲ្យបានឃ្វាលពួកជំនុំរបស់ព្រះអម្ចាស់...

– កិច្ចការ ២០៖២៨

# ការបង្កើតសិស្សផ្ទាល់ខ្លួន&និងជាក្រុម

វាជាការសំខាន់ណាស់ក្នុងការបើកអារម្មណ៍កថាដោយការអញ្ជើញមកចូលក្នុងប្រព័ន្ធនៃការបង្កើតសិស្ស ដោយមានការយល់ដឹងជាគោលថា ការបង្កើតសិស្សដោយចេតនា គឺវាមានលក្ខណៈផ្ទាល់ខ្លួន និងជាក្រុម។

**ការបង្កើតសិស្សផ្ទាល់ខ្លួន (បុគ្គល)៖**
**បង្ហឹក និងផ្តល់កំលាំងឲ្យសិស្សរីកចំរើនដោយខ្លួនឯង។**

មានរឿងមួយនិយាយពីក្មេងជំទង់ម្នាក់ដែលកំពុងជិះរថភ្លើង ហើយគាត់ភ្លេចចងខ្សែរស្បែកជើង។ អ្នកដំណើរក្នុងរថភ្លើង ប្រាប់ដល់ក្មេងជំទង់នោះ ហើយក្មេងនោះងក់ក្បាល តែមិនបានធ្វើអីទេ។ បីបួននាទីកន្លងទៅ អ្នកដំណើរនិយាយម្តងទៀត « អ្នកភ្លេចចងខ្សែរស្បែកជើង ខ្ញុំមិនចង់ឲ្យអ្នកទាក់ខ្សែរហើយដួលទេ។» ក្មេងជំទង់នោះនិយាយថា អរគុណ តែមិនបានធ្វើអ្វីទាំងអស់។ ពេលដែលអ្នកទាំងពីរត្រៀមខ្លួនចេញពីរថភ្លើង អ្នកដំណើរចាប់អារម្មណ៍ថា ស្បែកជើងក្មេងនោះនៅតែមិនចង់ខ្សែរ។ ពេលដែលក្មេងជំទង់នោះដើរចេញពីរថភ្លើង គាត់ជាន់លើខ្សែរស្បែកជើង ហើយដួលផ្កាប់មុខ។ អ្នកដំណើរនោះក៏ជួយលើកគាត់ឡើង ហើយសួរថា «ហេតុអ្វីអ្នកមិនចងខ្សែរស្បែកជើង?» ក្មេង នោះឆ្លើយថា «មិនដែលមានអ្នកណាបង្រៀនខ្ញុំឲ្យចេះចងខ្សែរស្បែកជើងទេ»

នៅទីអាស្នា សំបូរដោយសេចក្តីអធិប្បាយដែលនិយាយពី «គួរតែចេះ គួរតែចុះ»។ ថ្នាក់ថ្ងៃអាទិត្យនិយាយពីការជាច្រើនដែលទាក់ទងនិងការបង្កើតសិស្ស។ ប៉ុន្តែយើងយល់ខុសថា បើអ្នកណាម្នាក់ចេះប្រើពាក្យថា «គួរតែចេះ គួរតែចុះ» នោះពួកគេប្រាកដជាចេះ «របៀបធ្វើ»។ យើងត្រូវតែប្តូរពីការបង្រៀន ទៅជាការ

ហ្វឹកហ្វឺននិងផ្តល់កំឡាំង។ តើយើងបាននឹងកំពុងតែចងខ្សែរស្បែកជើងពួកសិស្ស ឬយើងកំពុងបង្រៀនពួកគេឲ្យចេះចងខ្សែរស្បែកជើង?

ខ្ញុំជឿថា យើងត្រូវរំលឹកមនុស្សគ្រប់រូបថា ការដើរតាមព្រះគ្រីស្ទ និងការពេញវ័យក្នុងភាពជាសិស្សរបស់ព្រះគ្រីស្ទ គឺជាដំណើរអស់មួយជីវិត។ នេះដូចជាការដែលយើងនិយាយក្នុងការថ្វាយបង្គំរាល់អាទិត្យ «នេះជាជំហានបន្ទាប់ដែលអ្នកគួរធ្វើដើម្បីធ្វើឲ្យជំនឿរបស់អ្នកកាន់តែរីកចំរើន។» នៅដើមឆ្នាំនិមួយៗ អ្នកអាចបង្កើតផែនការនៃការរីកចំរើន ផ្នែកវិញ្ញាណ ជាមួយក្រុមអ្នកដឹកនាំក្រុមជំនុំ។ ការនេះអាចជួយឲ្យមនុស្សគិតពីផែនការចេតនារបស់គេក្នុងការរីកចំរើនផ្នែកវិញ្ញាណ។ ការនេះក៏អាចជួយឲ្យក្រុមអ្នកដឹកនាំ ក្លាយទៅជាក្រុមសេចក្តីសន្យា ដែលវាមិនគ្រាន់តែបង្កើតជាព័ន្ធកិច្ចល្អៗនោះទេ  វាក៏ជួយឲ្យយើងជួយដាស់តឿនគ្នាចំពោះការពេញវ័យខាងវិញ្ញាណ។

**ការបង្កើតសិស្សជាក្រុម (ក្រុមជំនុំ)៖**
**ការធ្វើអ្វីគ្រប់យ៉ាងដែលយើងអាចធ្វើបាន ជាក្រុមជំនុំ ដើម្បីផ្តល់ឱកាសឲ្យពួកសិស្សរីកចំរើន និងពេញវ័យខាងសេចក្តីជំនឿ។**

ទោះជាភាសាក្នុងប្រព័ន្ធនៃការបង្កើតសិស្សដោយចេតនា ផ្តល់ការលើកទឹកចិត្ត ការហ្វឹកហ្វឺន និងផ្តល់អំណាច ដល់មនុស្សគ្រប់គ្នា ឲ្យមានការរីកចំរើនជាសិស្សក៏ដោយ ក៏យើងដែលជាអ្នកដឹកនាំក្រុមជំនុំ ចាប់ផ្តើមការងារដ៏លំបាកមួយនេះដោយធ្វើអ្វីគ្រប់យ៉ាង ដើម្បីបង្កើតឱកាសក្នុងក្រុមជំនុំរបស់យើងឲ្យរីកចំរើននិងពេញវ័យក្នុងសេចក្តីជំនឿ។

បើអ្នកមានសួនបន្លែមួយ នោះអ្នកដឹងថា ការខ្លះយើងអាចគ្រប់គ្រងបាន ការខ្លះយើងមិនអាច។ ដូច្នេះ តើអ្នកធ្វើយ៉ាងម៉េច? អ្នកប្រឹងធ្វើអ្វីដែលអ្នកអាចធ្វើបានដោយល្អអស់ពីចិត្ត។ អ្នកខំធ្វើដីឲ្យល្អបំផុត តាមដែលអ្នកអាចធ្វើបាន។ អ្នករកកន្លែងដែលទទួលបានពន្លឺថ្ងៃច្រើនបំផុត។ អ្នកស្រោចទឹកត្រឹមត្រូវ ដោយគិតថាពេលណាមានភ្លៀង ពេលណាអត់។ អ្នកចង់ឲ្យមានលក្ខណ៍ល្អបំផុតសំរាប់បន្លែរបស់អ្នក។ នេះគឺជាផ្នែកនៃការបង្កើតសិស្សជាក្រុមដោយចេតនា។

ការដែលយើងនិយាយថា «ការបង្កើតសិស្សដោយចេតនាទាមទារឲ្យមានការធ្វើជាបុគ្គល និងជាក្រុម» គឺមានន័យថា សិស្សត្រូវការទាំងពីរ ដើម្បីឃើញពីការរីកចំរើន និងការពេញវ័យ។ ការបង្កើតសិស្សដោយចេតនា មិនពឹងពាក់តែលើការខំប្រឹងរបស់បុគ្គល ឬការចូលរួមរបស់ក្រុមជំនុំ តែម្ខាងៗនោះទេ។ វាទាមទារទាំងសងខាង ហើយធ្វើដោយហ្មត់ចត់ នោះការរីកចំរើន និងការពេញវ័យ នឹងកើតឡើង។

# សូមចំណាយពេលបន្តិចៈ

## សូមពិភាក្សាសំនួរខាងក្រោមជាមួយអ្នកដឹកនាំៈ

1. តើក្រុមជំនុំមានផ្តល់កម្មវិធីអ្វីខ្លះដែលធ្វើឲ្យខ្ញុំរីកចំរើនក្នុងសេចក្តីជំនឿរបស់ខ្ញុំ?

2. តើវិធីណា ដែលក្រុមជំនុំធ្វើឲ្យខ្ញុំយល់ថា មានការទទួលខុសត្រូវចំពោះការរីកចំរើនផ្នែកជាសិស្ស?

3. តើខ្ញុំអាចធ្វើអ្វីផ្សេងទៀតបាន ដើម្បីឲ្យខ្ញុំមានការរីកចំរើន?

4. តើក្រុមជំនុំរបស់យើងធ្វើអ្វីគ្រប់យ៉ាងដែលអាចធ្វើបាន ដើម្បីផ្តល់ឱកាសឲ្យពួកសិស្សបានរីកចំរើន និងពេញវ័យ ដែរឬទេ? តើយើងមានចេតនាធ្វើវាទេ?

«ខ្ញុំជឿថា ដើម្បីរក
ឃើញដួងចិត្តមេត្តូ
ឌីស្ទ យើងត្រូវរកឲ្យ
ឃើញថា អ្វី របៀប
និងហេតុផល នៃ
ការបង្កើតសិស្ស។»

> ខ្ញុំមិនខ្លាចទេដែលថា មេថូឌីស្ទនឹងត្រូវបាត់បង់ក្នុងទ្វីបអាមេរិក ឬអឺរ៉ុប។ តែខ្ញុំខ្លាចថា គេរស់ដូចស្លាប់ ដោយមានតែសាសនា តែគ្មានអំណាច។ ហើយករណីនេះនឹងកើតឡើង បើសិនគេមិនប្រកាន់ផ្ទាប់គោលលិទ្ធិ ដែលប្រកាន់ផ្ទាប់នូវវិញ្ញាណ និងគោលការដែលគេបានចែងពីដំបូង។
>
> – John Wesley, from “Thougths Upon Methodism”

# ត្រូវការភាពច្បាស់លាស់៖ អ្វី, យ៉ាងម៉េច, ហេតុអ្វី

ពេលលោកវេស្លីសរសេរពាក្យទាំងនេះ គាត់បានបង្ហាញពីសេចក្តីភ័យខ្លាចថា ថ្ងៃណាមួយ មនុស្សដែលហៅថាមេថូឌីស្ទ អាចបាត់អំណាចដឹកនាំចលនាមេថូឌីស្ទ។ ហើយមេថូឌីស្ទអាចភ្លេចថាហេតុអ្វីបានមានចលនា មេថូឌីស្ទ កើតឡើង។ ហើយយើងអាចភ្លេចថាយើងជឿលើអ្វី ហើយហេតុអ្វីបានជាយើងជឿ។ យើងបាត់វិញ្ញាណដែលជាកំឡាំងជំរុញអំពើ និងសម្តី។ តើពេលនោះបានមកដល់ឬនៅ? តើយើងបានបាត់ការផ្តោតអារម្មណ៍លើភាពបរិសុទ្ធនៃដួងចិត្ត និងជីវិត ដែលបំផ្លាស់បំប្រែមនុស្សម្នាក់ៗ និងសហគមន៍? ខ្ញុំជឿថា ដើម្បីអាចរកឃើញអំណាចក្នុងអំណាចនៃដួងចិត្តមេថូឌីស្ទ យើងត្រូវរកឲ្យឃើញអ្វី របៀបម៉េច និងហេតុអ្វីនៃភាពជាសិស្ស។

## អ្វី

បើអ្នកនិយាយទៅកាន់អ្នកដឹកនាំក្រុមជំនុំភាគច្រើនថា «សូមប្រាប់ខ្ញុំពីអ្វីដែលក្រុមជំនុំរបស់អ្នកធ្វើ» នោះគេនឹងនិយាយពីសកម្មភាព និងព័ន្ធកិច្ចក្រុមជំនុំ៖ «យើងថ្វាយបង្គំម៉ោង ៨៖៣០ និង ១១៖០០។ ថ្នាក់ថ្ងៃអាទិត្យ នៅចន្លោះកម្មវិធីទាំងពីរ។ ថ្ងៃអាទិត្យទីពីរក្នុងខែនិមួយៗយើងមានអាហារពេលព្រឹក។ ខែមិថុនា យើងមានដំណើរបេសកកម្មដើម្បីជួសជុលផ្ទះ ហើយយើងមានការសិក្សាព្រះគម្ពីរល្ងាចថ្ងៃពុធ។» ការទាំងអស់នេះល្អ ហើយវាគួរជាផ្នែកមួយនៃក្រុមជំនុំ តែនេះមិនគួរជាច

ម្លើយរបស់យើងចំពោះសំនួរ «តើក្រុមជំនុំរបស់អ្នកធ្វើអ្វី?»

តើអ្វីទៅជាបេសកកម្មរបស់ ក្រុមជំនុំយូណៃធីតមេថូឌីស្ទ?

**បង្កើតសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីបំផ្លាស់បំប្រែពិភពលោក។**
(¶១២០ សៀវភៅវិន័យឆ្នាំ២០១៦)

ពេលដែលគេសួរថា តើក្រុមជំនុំរបស់យើងធ្វើអ្វី ចំឡើយរបស់យើងគួរតែថា «យើងបង្កើតសិស្ស»

មានមនុស្សជាច្រើនក្នុងក្រុមជំនុំរបស់យើងដែលចងចាំឃ្លាបេសកកម្មរបស់យើង តែយើងត្រូវធ្វើតាមបេសកកម្មនេះ។ យើងធ្វើការល្អជាច្រើន ក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ តែយើងមិនទាន់បានបង្កើតសិស្សនោះទេ។

# អ្វី & របៀប៖ សំនួរពីរដែលសួរដដែលៗ

ពេលខ្ញុំធ្វើដំណើរជុំវិញប្រទេស ដើម្បីនិយាយពីការបង្កើតសិស្សដោយចេតនា ហើយស្តាប់គ្រូគង្វាល ចាស់ទុំ បុគ្គលិកមហាសន្និបាត លោកអភិបាល មានសំនួរពីរលេចឡើងក្នុងការពិភាក្សានោះ។

**តើសិស្សជាអ្វី?**
**តើការបង្កើតសិស្សធ្វើដោយរបៀបណា?**

វាត្រឹមត្រូវ ក្នុងការសួរខ្លួនឯង និងក្រុមជំនុំ តើផ្នែកណាមួយដែលយើងធ្វើក្នុងការបង្កើត សិស្ស ហើយតើព្រះចូលក្នុង ដំណើរការនេះនៅកន្លែងណាដែរ? ព្រោះយើងជឿលើអាថ៌កំបាំងនៃព្រះគុណរបស់ព្រះ--ដំបូង រាប់ជាបរិសុទ្ធ និងញែកជាបរិសុទ្ធ--ដែលកំពុងធ្វើការក្នុងជីវិតមនុស្សគ្រប់គ្នា។ បញ្ហានៅត្រង់ថា អាថ៌កំបាំងនៃព្រះគុណរបស់ព្រះ មិនមែនជាហេតុផលសំរាប់សំនួរទាំងពីរនេះទេ។ អ្វីដែលខ្ញុំភ័យខ្លាចនោះគឺ សំនួរទាំងពីរនេះបង្ហាញពីការដែលយើងចង់លះបង់ការទទួលខុសត្រូវ ក្នុងដំណើរការបង្កើតសិស្ស។ និយាយតាមត្រង់ បើយើងមិនដឹងថាអ្វីជាសិស្ស ឬរបៀបបង្កើតសិស្ស យើងនឹងមិនអាចបង្កើតសិស្សបានទេ។ ការខ្វះភាពច្បាស់លាស់ ធ្វើឲ្យយើងមិនអាចធ្វើការងារដែលលំបាក និងមានចេតនា ក្នុងការបង្កើតសិស្សនោះទេ។ ពិតណាស់ ថាវាគ្មានវិធីបង្កើតសិស្សដូចពុម្ពកាត់នំទេ ហើយដំណើររបស់សិស្ស និងក្រុមជំនុំនិមួយៗ គឺមានភាពពិសេសរាងៗខ្លួន។ ហើយយើងដែលជាសិស្សរបស់ព្រះគ្រីស្ទ មានតួនាទីក្នុងការអភិវឌ្ឍន៍ភាពជាសិស្សរៀងៗខ្លួន ក្នុងការដែលយើងដាស់តឿនគ្នា និងក្នុងការដែលយើងបង្កើតប្រព័ន្ធនៃការបង្កើតសិស្សដោយចេតនា។

យើងត្រូវចូលរួមចំណែកក្នុងដំណើរការនៃការបង្កើតសិស្ស ដែលព្រះគ្រីស្ទបានចាត់យើងមក៖

> **«ដូច្នេះចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនៅព្រះនាម ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្តី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។ អាម៉ែន។**
>
> **ម៉ាថាយ ២៨៖១៩-២០**

គន្លឹះនៃបទគម្ពីរនេះគឺពាក្យថា «ទៅ»។ យើងជាជំនឿដែលចេញទៅ។ បេសកកម្មរបស់និកាយយើង គឺចាក់ឫសក្នុងមហាបេសកកម្ម។ យើងធ្វើបានល្អបំផុត ពេលយើងចេញទៅ។ ស្មារតីរបស់ចលនាមេថូឌីស្ទ គឺស្តែងចេញពីការចេញទៅរកមនុស្សដោយគោលបំណងក្នុងការបង្កើតសិស្ស។ យើងភ្លេចអំណាចដែលជាថាមពលសំរាប់ចិត្តឆេះឆួលរបស់យើង ក្នុងការបង្កើតសិស្ស ដែលមានក្នុងការខំប្រឹងប្រែងឆ្លើយតប ចំពោះការត្រាស់ហៅនៃមហាបេសកកម្ម។

បើយើងនៅតែព្រងើយកណ្តើយ មិនដឹងពីអ្វី ឬរបៀប នោះយើងត្រូវតែទៅមើលបេសកកម្មរបស់ក្រុមជំនុំយូណៃធីតមេថូឌីស្ទម្តងទៀត។ ហើយបើយើងជឿលើឃ្លាបេសកកម្មនេះ យើងត្រូវច្បាស់លាស់ចំពោះសំនួរទាំងពីរនេះ។ យើងត្រូវដឹងពីអត្តសញ្ញាណនៃពួកសិស្ស យើងត្រូវដឹងពីអ្វីដែលយើងចង់បាន (តើពួកសិស្សបែបណា ដែលក្រុមជំនុំយើងចង់បង្កើត?) ហើយយើងត្រូវគិតដោយចេតនា ថាតើពន្ធកិច្ចនិងឱកាសរបស់ក្រុមជំនុំយើងងធ្វើការជាមួយគ្នា ដើម្បីចេញជាប្រព័ន្ធបង្កើតសិស្ស។ ខ្ញុំសង្ឃឹមថា នៅឆ្នាំបន្តបន្ទាប់ ពេលគ្នាយើងជាច្រើនចូលរួមក្នុងចលនានៃការ បង្កើតសិស្សដោយចេតនា។បន្ថែមលើឃ្លាបេសកកម្មនេះគ្រាប់គ្នាដែលអង្គុយលើកៅអីក្នុងព្រះវិហារត្រូវអាចនិយាយថាតើសិស្សជាអ្វីហើយយល់ពីរបៀបនៃការបង្កើតសិស្ស។

# ហេតុអ្វី

ភាពច្បាស់លាស់នៃ អ្វី និងរបៀប គឺសំខាន់ណាស់ តែខ្ញុំជឿថាយើងត្រូវតែដកមួយជំហានថយក្រោយសិន ហើយឆ្លើយសំនួរថា៖ ហេតុអ្វីបង្កើតសិស្ស?

ក្នុងសៀវភៅគាត់ដែលមានចំណងជើងថា «ចាប់ផ្តើមដោយហេតុអ្វី» លោក Simon Sinek បង្ហាញពីរបៀបដែលអ្នកដឹកនាំ ចលនា និងក្រុមហ៊ុនល្អៗ ដំណើរការចេញពីមូលហេតុរបស់គេ។ Simon ពន្យល់ថា ក្រុមហ៊ុនភាគច្រើនដឹងពីអ្វីដែលពួកគេធ្វើ ខ្លះដឹងពីរបៀបដែលគេធ្វើ តែមានតិចណាស់ដែលដឹងពីមូលហេតុដែលគេធ្វើ។ គាត់ហៅការនេះថា រង្វង់មាស (The Golden Circle)

(សូមមើល តារាង A)

«ពេលខ្ញុំនិយាយថា ហេតុអ្វី ខ្ញុំមិនចង់មានន័យពីការរកលុយ—ដែលជាលទ្ធផលទេ។ ពាក្យថា ហេតុអ្វី ខ្ញុំមានន័យថា តើអ្វីទៅជាគោលបំណង មូលហេតុ ឬជំនឿ? ហេតុអ្វីបានជាមានក្រុមហ៊ុនរបស់អ្នក? ហេតុអ្វីអ្នក ក្រោកពីគេងរាល់ព្រឹក? ចុះវាមានប្រយោជន៍អីសំរាប់អ្នកដទៃ?

– Simon Sinek, from *Start with Why*



**តារាង A**

ទោះជាលោក Sinek និយាយទៅកាន់ក្រុមហ៊ុនជំនួញធំៗ ខ្ញុំជឿថាមេរៀននេះគឺដូចគ្នាសំរាប់ក្រុមជំនុំដែរ។ តើយើងអាចពន្យល់ពីមូលហេតុរបស់យើងបានទេ? ពេលយើងមើលឃ្លានេះ យើងអាចជំនួសពាក្យថា «រកលុយ» ដោយពាក្យ «ឲ្យមានមនុស្សពេញក្រុមជំនុំ»។ ការដែលមានមនុស្សពេញក្រុមជំនុំ គឺជាលទ្ធផលមួយ តែវាមិនទាក់ទងនិងហេតុផល របស់យើងគេ ហើយក៏មិនទាក់ទងនិងការបង្កើតសិស្សដែរ។ ហេតុផលដែលយើងបង្កើតសិស្ស គឺជាគោលបំណង ជាដើមហេតុ និងជាជំនឿយើង។ វាស៊ីជម្រៅទៅដល់មូលហេតុដែលយើងកើតមាន។ ហេតុអ្វីបានក្រុមជំនុំរបស់អ្នកកើតមាន ហើយវាមានប្រយោជន៍សំរាប់អ្នកដទៃ?

ពេលសួរ «ហេតុអ្វីបានជាអ្នកនៅទីនេះ (ក្នុងក្រុមជំនុំនេះ ក្នុងកន្លែងនេះ)?» តើអ្នកឆ្លើយយ៉ាងម៉េច? ខ្ញុំសួរសំនួរនេះ ពេលខ្ញុំទៅលេងក្រុមជំនុំផ្សេងៗ ហើយចំនួនមនុស្សផ្សេងៗគ្នា តែលទ្ធផលជាទូទៅគឺដូចគ្នា៖

- **តិចជា៥%** និយាយថាគេរកឃើញក្រុមជំនុំនេះដោយខ្លួនឯង
- **៥-១០%** និយាយថាមានគេអញ្ជើញគាត់មកក្រុមជំនុំនេះ
- **៨០% ឬច្រើនជាង** និយាយថា គេ«កើត» ក្នុង ក្រុមជំនុំមេថូឌីស្ទ ហើយតែងតែចូលរួមក្រុមជំនុំមេថូឌីស្ទ នៅក្នុងទីក្រុងដែលគេនៅ។ ហើយភាគច្រើននៃក្រុមនេះ (៦០-៧០%) និយាយថា គេមកក្រុមជំនុំនេះយូរមកហើយ ឪពុកម្តាយយាយតាគេ ជាសមាជិកក្រុមជំនុំនេះ ដូច្នេះហើយគេក៏ចូលរួមដែរទៅ។

បញ្ហានៅត្រង់ថា ការដែលយើងនៅកន្លែងមួយកាន់តែយូរ នោះយើងនឹងភ្លេចពីហេតុផលដែលយើងនៅកន្លែងនោះ

ខ្ញុំអះអាងថា មេថូឌីស្ទច្រើនណាស់ដែលភ្លេចពីហេតុផលជាសិស្ស សំរាប់ក្រុមជំនុំមួយ ដូច្នេះភ្លេចពីហេតុផលក្នុងការបង្កើតសិស្ស។ ដែលយើងព្យាយាមបង្ហាញថាតើ

សិស្សជាអ្វី របៀបបង្កើតសិស្ស ការសំខាន់បំផុតដែលយើងជាសិស្ស របស់ព្រះគ្រីស្ទអាចធ្វើ គឺជាការដែលយើងតភ្ជាប់មូលហេតុរបស់យើង។[2]

# ចំណាយពេលបន្តិចៈ

## ពិភាក្សាសំនួរខាងក្រោមជាមួយអ្នកដឹកនាំៈ

1. ហេតុអ្វីខ្ញុំនៅទីនេះ (ក្នុងក្រុមជំនុំនេះ)?
2. អ្វីដែលនាំខ្ញុំមកទីនេះ?
3. ហេតុអ្វីខ្ញុំមិនទៅកន្លែងផ្សេង? អ្វីទៅដែលធ្វើឲ្យខ្ញុំនៅទីនេះ?
4. ហេតុអ្វីកន្លែងនេះមានសារៈសំខាន់សំរាប់ខ្ញុំ?

[2] ជាធនធានផ្សេងទៀត ខ្ញុំអញ្ជើញអ្នកឲ្យអានសៀវភៅរបស់លោក Simon Sinek ដែលមានចំណងជើងថា Start with Why។ ក្នុងសៀវភៅនេះ គាត់បានរំលេចពីជោគជ័យនៃក្រុមហ៊ុន Apple, The Wright Brothers, and Marin Luther King, Jr. and the Civil Rights Movement through the lens of the Golden Circle. ឬមើល TED Talk “How Great Leaders Inspire Action” www.ted.com/talks/simon_sinek_how_great_leaders_inspire_action

«ដូចជាកូនក្មេង
ដែលតែងតែសួរ
ដដែលថា «ហេតុអ្វី»
ពួកសិស្សព្រះគ្រីស្ទ
ត្រូវព្យាយាម
ច្រើនដង ដើម្បីរក
ឃើញពីហេតុផលនៃ
ការបង្កើតសិស្ស។»

ហើយពេលដែលយើងត្រូវបានរាប់ជាបរិសុទ្ធ ការញែកជាបរិសុទ្ធចាប់ផ្តើម ពេលនោះឯង ។ ពេលនោះ គឺយើង បាន «កើតជាថ្មី» «កើតមកពីខាងលើ» «កើតចេញពីព្រះវិញ្ញាណ»។ មានការផ្លាស់ប្តូរប្រាកដ។ យើងត្រូវបានស្អាងជាថ្មីពី ខាងក្នុង ដោយអំណាចរបស់ព្រះ។ យើងទទួលអារម្មណ៍ «សេចក្តីស្រឡាញ់របស់ព្រះមានក្នុងដួងចិត្តយើង ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានប្រទានមកយើង» ដែលបង្កើតសេចក្តីស្រឡាញ់ដល់មនុស្សទាំងអស់ ហើយជាពិសេសគឺ សម្រាប់រាស្ត្ររបស់ព្រះ ដោយបោះចោលការស្រឡាញ់លោកិយ ការស្រឡាញ់សេចក្តីភ្លើតភ្លើន ភាពសុខស្រួស កិត្តិយស លុយ អំណួត កំហឹង អត្មានិយម និងគ្រប់ទាំងការអាក្រក់ ឬនិយាយបានថា ការផ្លាស់ប្តូរ «របស់លោកិយ តណ្ហា និងការអាក្រក់ » ទៅជា «ដួងចិត្តក្នុងព្រះគ្រីស្ទ»

– John Wesley, Sermon “The Scripture Way of Salvation”[3]

# ការយល់ & ការរកឃើញ ពី «ហេតុអ្វី» នៃការបង្កើតសិស្ស

នេះជាមូលហេតុ «យើងត្រូវបានស្អាងជាថ្មីពីខាងក្នុង ដោយអំណាចរបស់ព្រះ... បង្កើតសេចក្តីស្រឡាញ់ដល់មនុស្ស គ្រប់គ្នា។» សូមឲ្យមានចលនានៃការស្អាងជាថ្មីពីខាងក្នុង ហើយអាចមើលឃើញ និងស្រឡាញ់មនុស្សគ្រប់គ្នា។ តើចលនារបៀបនេះទាមទារអ្វីខ្លះ? ការរកឃើញនៃការបង្កើតសិស្សដោយចេតនា។

ប៉ុន្មានឆ្នាំចុងក្រោយនេះ យើងពូកែខាងបង្ហាញពីអ្វីដែលយើងគួរធ្វើ។ ក្រុមជំនុំយើងគួរមានការថ្វាយបង្គំដែលលើកទឹកចិត្ត មានព័ន្ធកិច្ចដែលទាក់ទងនិងសហគមន៍ មានក្រុមតូច មានព័ន្ធកិច្ចកុមារ និងយុវជន ការផ្សាយដំណឹងល្អ ការដាក់ដង្វាយ

[3] John Wesley, Sermon “The Scripture Way of Salvation” (1765) I.4 (Works, 2:158)

និងការផ្សេងៗទៀត។ បញ្ហាដែលយើងដឹង និងព្យាយាមបំពេញតាមការទាំងនោះ គឺធ្វើឲ្យយើងចាក ឆ្ងាយពីមូលហេតុរបស់យើង ហើយការទាំងនោះក្លាយទៅជាការងារជាប្រចាំ ដែលធ្វើឲ្យយើងអស់កំលាំងចិត្ត។

តើការងារណាខ្លះ ដែលក្លាយជាការងារជាប្រចាំ-ការងារដែលយើងមានអារម្មណ៍ថាត្រូវតែធ្វើ?

អ្វីដែលយើងបានរៀនពីសេចក្តីអធិប្បាយរបស់លោក ចន វេស្លី និងចលនាមេថូឌីស្ទពីដំបូង គឺថាអ្វីដែលគេនិយាយ និងធ្វើគឺស្តែងចេញពីមូលហេតុ។ ការអធិប្បាយ និងការបង្រៀនបែបនេះ ចាក់ឬសចូលក្នុងមូលហេតុ ដែលបង្កើត ជាសេចក្តីអំណរ និងគោលបំណង និងស្រេកឃ្លានចង់ធ្វើ ក្នុងនាមជារូបកាយព្រះគ្រីស្ទ (ក្រុមតូចទាក់ទងនិងសហគមន៍ ការផ្សាយដំណឹងល្អ និងការថ្វាយដង្វាយ ។ល។)

អ្នកដែលចង់ធ្វើតាមលោកវេស្លី និងចលនាមេថូឌីស្ទ សួរខ្លួនឯងថា៖

តើខ្ញុំនឹងរីកចំរើនក្នុងសេចក្តីជំនឿថ្មីនេះយ៉ាងម៉េច?
តើខ្ញុំអាចប្រើអំណោយទានរបស់ខ្ញុំដោយរបៀបណា?
តើខ្ញុំអាចថ្វាយដង្វាយដោយរបៀបណា?
តើខ្ញុំអាចបំរើអ្នកដទៃ ដោយរបៀបណា?
តើខ្ញុំអាចអញ្ជើញមិត្តភ័ក្រ ខ្ញុំបានទេ?

ពេលយើងយល់ពីមូលហេតុនៃការបង្កើតសិស្ស យើងរីកចំរើនក្នុងសេចក្តីជំនឿ ក្នុងការទំនាក់ទំនងជាមួយអ្នកដទៃ ក្លាយជាមនុស្សសប្បុរស គិត និងធ្វើ លើសពីខ្លួនឯង និងអញ្ជើញអ្នកដទៃឲ្យ ចូលមកក្នុងជីវិតថ្មីក្នុងព្រះគ្រីស្ទ។ ការធ្វើជាសិស្សរបស់ព្រះគ្រីស្ទ មិនមែនជាតារាងនៃការដែលគួរធ្វើ តែវាជាបែបផែនជីវិត។ បើយើងស្វែងរកឃើញការយល់ដឹងពីមូលហេតុ ភាពជាសិស្សនិងក្លាយជា បែបផែនជីវិត ដែលមិនអាចជៀសផុត។ យើងមិនតម្រូវឲ្យអញ្ជើញមិត្តភ័ក្រមកក្រុមជំនុំនោះទេ តែយើងសប្បាយចិត្តនិងធ្វើ។ យើងមិនតម្រូវឲ្យចូលរួមក្រុមតូច ឬអានព្រះគម្ពីរទេ គឺយើងចង់។ ពេលយើងយល់ពីហេតុផលនៃភាពជាសិស្ស ហើងចង់រីកចម្រើន និងពេញវ័យជាអ្នកដើរតាមព្រះយេស៊ូវ នោះការផ្លាស់ប្តូរក្នុងខ្លួនយើង នឹងធ្វើឲ្យមានសេចក្តីស្រេកឃ្លាន ក្នុងការធ្វើតាមអ្វីដែលព្រះគ្រាស់ហៅឲ្យយើងធ្វើ។ បើយើងគ្មានការនេះទេ យើងត្រូវតែស្វែងយល់ពីមូលហេតុម្តងទៀត។

# ហេតុផលជ្រៅ

ឪពុកម្តាយធុញនិងសំនួរ «ហេតុអ្វី?» ពេលដែលក្មេងៗអភិវឌ្ឍន៍ខួរក្បាល គេតែងចង់យល់ថា ហេតុអ្វីមនុស្សធ្វើការងារណាមួយ។ ខ្ញុំចាំពេលកូនខ្ញុំសួរថា «ហេតុអ្វី?»

។ ថ្ងៃណា ខ្ញុំបំពេញតួនាទីជាឪពុកបានល្អ នោះខ្ញុំនឹងព្យាយាមឆ្លើយដោយប្រុងប្រយ័ត្ន។ ជួនកាលចំលើយ របស់ខ្ញុំមិនពេញលេញទេ នោះគេនឹងសួរ «ហេតុអ្វី»ម្តងទៀត។ (ឪពុកម្តាយដឹងថា ពេលដែល គេសួរ «ហេតុអ្វី» កាន់តែច្រើន នោះគឺមានន័យថាឪពុកម្តាយកាន់តែអស់ការអត់ធ្មត់) បើខ្ញុំមិនទាន់ឆ្លើយបានល្អ ចំពោះសំនួរ «ហេតុអ្វី» របស់កូនលើកទីបី ទីបួនបានទេ នោះចំឡើយគឺថា «មកពីវាអញ្ចឹង» ឬ «ព្រោះប៉ាថាអញ្ចឹង»។ យើងដឹងហើយថា ចំលើយនេះមិនឆ្លើយតបនិងសំនួរ «ហេតុអ្វី» ទេ។ អញ្ចឹង ហេតុអ្វីបានជាពេលដែលយើងសួរសារ «ហេតុអីបានជាយើងបង្កើតសិស្ស យើងតែងឆ្លើយថា «ព្រោះព្រះយេស៊ូវមានបន្ទូលអញ្ចឹង»? ពិតណាស់ថាព្រះអង្គមានបន្ទូលដូច្នេះ តែវាមិនមែនជាចម្លើយល្អទេ។ «ព្រោះទ្រង់មានបន្ទូលអញ្ចឹង» មិនមែនជាចំលើយលើកទឹកចិត្តទេ។ ដូចដែលកូនក្មេងសួរម្តងហើយម្តងទៀត «ហេតុអ្វី» ដែរ សិស្សរបស់ព្រះគ្រីស្ទត្រូវព្យាយាមច្រើនដងដើម្បីដឹងពីហេតុផលក្នុងការបង្កើតសិស្ស។

ការដែលយើងមិនយល់ឲ្យច្បាស់ពីមូលហេតុក្នុងការបង្កើតសិស្ស ធ្វើឲ្យយើងខ្សោយក្នុងការបង្កើតសិស្ស ហើយវាធ្វើឲ្យយើងខ្សោយក្នុងការធ្វើជាស្មរបន្ទាល់ដល់ពិភពលោក។ មនុស្សម្នាក់ មិនអាចឲ្យនូវអ្វីដែលគេគ្មាននោះទេ។ បើយើងមិនដឹងថា ហេតុអ្វីយើងជាសិស្សទ្រង់ផង ធ្វើម៉េចឲ្យយើងអាចអញ្ជើញអ្នកដទៃឲ្យដើរតាមព្រះគ្រីស្ទអស់មួយជីវិតបាន? ហើយក្រុមជំនុំយើង ធ្វើការបានល្អក្នុងការ (កាត់បន្ថយជំងឺគ្រុនចាញ់ បង្កើនសុខភាពពិភពលោក ផ្តល់អាហារ និងកម្មវិធីក្រោយម៉ោងសាលា ។ល។) តែយើងមិនអាចពន្យល់ថាហេតុអ្វីយើងធ្វើការទាំងអស់នេះ នោះយើងគ្រាន់តែជាអង្គារមិនរកប្រាក់ចំណូលមួយដែលធ្វើការល្អ។

# ចំណាយពេលបន្តិច៖

**សូមមើលវីដេអូក្នុង Youtube ដែលមានចំណងជើងថា ដឹងហេតុផលរបស់អ្នក ដោយលោក Michael, Jr.**

www.UMCdiscipleship.org/knowyourwhy

1. ហេតុអ្វីយើងបង្កើតសិស្ស?

2. ហេតុអ្វីយើងចែកចាយសេចក្តីជំនឿរបស់យើង?

3. តើយើងមានអ្វីដែលយើងជឿថាអ្នកដទៃត្រូវការដែរឬទេ?

# ស្វែងយល់ពី «ហេតុអ្វី» របស់យើង ឡើងវិញ

ការស្វែងយល់ពី «ហេតុអ្វី» របស់យើងឡើងវិញ ក្នុងគ្រប់ផ្នែកនៃការបង្កើតសិស្ស គឺជាជំហ៊ានទីមួយ ទៅកាន់ការបង្កើតសិស្សដោយចេតនាក្នុងក្រុមជំនុំរបស់អ្នក។ ឧទាហរណ៍៖ តើការស្ម័គ្រចិត្តក្នុងបន្ទប់កុមារ មានទាក់ទងអ្វីនិងការបង្កើតសិស្ស? ជាទូទៅ ក្នុងក្រុមជំនុំយើងយល់ថា ការមានបុគ្គលិកក្នុងបន្ទប់កុមារ គឺជាអ្វីដែលយើងត្រូវតែមាន។ ដូច្នេះយើងត្រូវមានការបង្វឹកផ្នែក សុវត្ថិភាពក្នុងក្រុមជំនុំ Safe Santuaries® ការឆែកប្រវត្តិរូប មានបញ្ជីចុះឈ្មោះ និងក្តារប្រកាសដំណឹង។ ការរកមនុស្សមកធ្វើការក្នុងបន្ទប់កុមារ អាចជាការងារដែលយើងត្រូវតែធ្វើ។ ប៉ុន្តែពេលយើងស្វែងយល់ពី «ហេតុអ្វី»របស់យើង ហើយភ្ជាប់វាជាមួយការបង្កើតសិស្ស នោះយើងនឹងស្វែងយល់ថា គ្រប់ទាំងតួនាទីមានទំនាក់ទំនងយ៉ាងស៊ីជម្រៅ សំរាប់គោលបំណងក្នុងការ បង្កើតសិស្ស។ តើវាយ៉ាងម៉េចដែរ បើការបំពេញបុគ្គលិកក្នុងបន្ទប់កុមារ កើតចេញពីហេតុផល នៃការបង្កើតសិស្ស? យើងប្រហែលជាត្រូវសួរដូច្នេះ៖

> បេសកកម្មក្នុងក្រុមជំនុំរបស់យើងគឺ បង្កើតសិស្សរបស់ព្រះគ្រីស្ទ ដើម្បីផ្លាស់ប្រែពិភពលោក។ ពេលអ្នកចុះឈ្មោះជាបុគ្គលិកក្នុងបន្ទប់កុមារ អ្នកសហការណ៍ជាមួយព្រះក្នុងការអប់រំកុមារ បង្ហាញពីព្រះគុណព្រះដល់ពួកគេ។ ហើយអរគុណសំរាប់ការបំរើរបស់អ្នកក្នុងបន្ទប់កុមារ ម្តាយឪពុកកុមារនោះនឹងអាចថ្វាយបង្គំពេញលេញ ក្នុងថ្ងៃអាទិត្យ ដែលជួយឲ្យគេរីកចំរើន និងពេញវ័យក្នុងសេចក្តីជំនឿរបស់គេ។ អរគុណដែលអ្នកចូលរួមក្នុងការបង្កើតសិស្ស។

បើយើងយល់ ហើយធ្វើការទំនាក់ទំនង់ពី ហេតុផលនៃការបង្កើតសិស្ស ដោយចេតនា ក្នុងគ្រប់ ទាំងការដែលយើងធ្វើ នោះយើងនឹងអាចបន្តចលនាដើមរបស់ព្រះយេស៊ូវ បន្តដោយចលនា មេថូឌីស្ទដើម ដែលបន្តលើកទឹកចិត្តឲ្យយើងធ្វើមកដល់ពេលនេះ។

# សូមចំណាយពេលបន្តិច៖

**គ្រប់ផ្នែកនៃក្រុមជំនុំរបស់យើងត្រូវយល់ពី «ហេតុអ្វី» និងយល់ពីរបៀបដែលវាទាក់ទងនិងការបង្កើតសិស្ស។**

1. តើក្នុងក្រុមជំនុំមានតួនាទីអ្វីខ្លះ ហើយយើងផ្សារភ្ជាប់វានិងការបង្កើតសិស្សយ៉ាងដូចម្ដេច?

2. តើអ្នកជួយឲ្យអស់ដទៃយល់ពី «ហេតុអ្វី» របស់គេ ដោយរបៀបណា?

3. តើអ្នកជួយឲ្យអស់ដទៃឲ្យភ្ជាប់តួនាទីរបស់គេទៅនិងការបង្កើតសិស្ស ដោយរបៀបណា?

«សិស្សគឺជាម្នាក់
ដែលស្គាល់ពី
ព្រះគ្រីស្ទ រីកចំរើន
ក្នុងព្រះគ្រីស្ទ បំរើ
ព្រះគ្រីស្ទ ហើយ
ប្រាប់គេពីព្រះគ្រីស្ទ។»

នាយកក្រុមហ៊ុនឡានបានទៅទស្សនារោងចក្រនៅប្រទេសជប៉ុន ហើយនៅកន្លែងដែលគេដាក់ ទ្វារឡានជាប់និងត្រចៀកទ្វា វាដូចជានៅស្រុកអាមេរិកដែរ។ តែមានអ្វីមួយដែលបាត់។ នៅសហរដ្ឋ ត្រូវមានកម្មករម្នាក់ត្រូវយកញញួរជ័រមកដំលើទ្វា ដើម្បីឲ្យវាចូលស៊ុបល្អ។ នៅជប៉ុន ការងារនេះអត់មានទេ។ ប្រធានក្រុមហ៊ុនអាមេរិកសួរថា តើពេលណាទើបត្រូវមានអ្នកមកពិនិត្យថាទ្វារឡានចូលស៊ុបល្អ? ជនជាតិជប៉ុនដែលជាអ្នកនាំផ្លូវ ញញឹម ហើយនិយាយថា «យើងដឹងថាវាចូលស៊ុបពេលយើងរចនាវា។» នៅរោងចក្រផលិតឡានរបស់ជប៉ុន គេមិនស្វែងរកបញ្ហា ហើយរកដំណោះស្រាយតាមក្រោយទេ។ គេរចនាអ្វីដែលគេចង់បានតាំងពីដំបូង។ បើគេមិនទទួលបានអ្វីដែលគេចង់បានទេ នោះគេដឹងថាវាជាកំហុសដែលគេធ្វើតាំងពីមុនមក។

– Simon Sinek, from 'Start with Why'[4]

# ប្រព័ន្ធបង្កើតសិស្ស ដោយចេតនា

## ប្រព័ន្ធហេតុអី?

ទោះជាអ្នកដឹងឬអត់ អ្នកមានប្រព័ន្ធបង្កើតសិស្សក្នុងក្រុមជំនុំអ្នករួចហើយ។ ប្រព័ន្ធបច្ចុប្បន្ន និងផលិតអ្វីដែលគេចង់ឲ្យវាផលិត។ ពេលយើងចាប់ផ្តើមគិតពីប្រព័ន្ធរបស់ក្រុមជំនុំយើង យើងអាចចាប់ផ្តើមគិតដោយចេតនា ថាតើប្រព័ន្ធយើងនេះផលិតអ្វី? ការបង្កើតសិស្សដោយចេតនាមានន័យថា យើងដឹង ហើយបានរៀបគំរោងច្រើនវិធី ដែលជួយឲ្យអ្នកដែលមានជំនឿថ្មី ចូលមកក្នុងប្រព័ន្ធបង្កើតសិស្សរបស់ក្រុមជំនុំ ហើយនឹងធ្វើដំណើរឆ្ពោះទៅរក ភាពពេញវ័យផ្នែកជំនឿ បន្ទាប់មកយើងនឹងប្រាប់ពីឪកាសដែលពួកសិស្សមានក្នុងក្រុមជំនុំហើយផ្តល់វិធីក្នុងការវាយតំលៃខ្លួនឯង ហើយពិចារណាជំហ៊ានបន្ទាប់ សំរាប់ដំណើរខាងព្រលឹងវិញ្ញាណរបស់គេ។ យើងសង្ឃឹមថា ក្រុមជំនុំ និងមហាសន្និបាទនឹងគិតដោយចេតនាហើយយើងនឹងបំបាត់ការបង្កើតសិស្សដោយចៃដន្យ «យើងមិនដឹងដែរ៖ មនុស្សមក ហើយអ្វីៗក៏កើតឡើង ហើយពួកសិស្សក៏បានបង្កើត។»

[4] *Start with Why,* Simon Sinek, Pg. 14-15

# បរិបទ ភាសា និងកម្មសិទ្ធិ

ពេលយើងធ្វើតាមគោលការណ៍គោល នៃប្រព័ន្ធបង្កើតសិស្សជាប្រពន្ធ័ យើងសូមឲ្យអ្នកធ្វើជាម្ចាស់ប្រពន្ធ័នេះ។ ក្រុមជំនុំនិមួយៗមានបរិបទផ្សេងៗគ្នា។ បរិបទរបស់អ្នកមានភាសាពិសេសរបស់អ្នក។ សូមកែសម្រួលតាមជាក់ស្តែង។ ការដែលលោកអ្នកធ្វើឲ្យភាសា និងប្រពន្ធ័សមស្របតាមបរិបទរបស់អ្នក នោះអ្នកដឹកនាំទាំងអស់នឹងគ្រប់គ្រងលើប្រពន្ធ័ដែលគេបង្កើត។ តាមពិត សៀវភៅនេះនឹងមិនមានប្រយោជន៍អ្វីទេ បើអ្នកមិនយកទៅប្រើ និងបង្កើតប្រពន្ធ័ដោយខ្លួនឯង។ គោលបំណងរបស់យើងគឺមិនមែនឲ្យអ្នកទទួលយកប្រពន្ធ័ពីយើងនោះទេ តែគឺដើម្បីឲ្យអ្នកមានចេតនាក្នុងការបង្កើតប្រពន្ធ័របស់អ្នក។

# តើសិស្សជាអ្វី?

ជាសមញ្ញ។ មនុស្សអាចពន្យល់ពាក្យថា សិស្ស។ អ្នកគួរអនុញ្ញាតិក្រុមជំនុំប្រើពាក្យដែលគេចង់បាន ដើម្បីងាយស្រួលចាំ។

អ្នកអាចប្រើការយល់តាមបែបលោកវេស្លី ចំពោះការបង្កើតសិស្ស ដោយប្រើច្បាប់ទូទៅនៃការបង្កើតសិស្ស៖

> សិស្សជាអ្នកធ្វើបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទក្នុងពិភពលោក ដែលដើរតាមការបង្រៀន តាមរយៈកិច្ចការនៃសេចក្តីមេត្តា យុត្តិធម៌ ការថ្វាយបង្គំ និងការសិក្សាក្រោមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ។[5]

ខ្ញុំតែងប្រើការអះអាង៖

> សិស្សជាអ្នកដែលស្គាល់ព្រះគ្រីស្ទ ដែលរីកចំរើនក្នុងព្រះគ្រីស្ទ បំរើព្រះគ្រីស្ទ និងចែកចាយពីព្រះគ្រីស្ទ។

ភាសានេះអាចកែតាមបរិបទរបស់អ្នក។ ការសំខាន់គឺថា អ្នកចំណាយពេលដើម្បីបង្កើត និងពន្យល់ឲ្យច្បាស់ពីការបង្កើតសិស្ស។ លោក Zig Ziglar មានប្រសាសន៍ថា «បើអ្នកមិនតម្រង់ទីណាមួយទេ នោះអ្នកនឹងទទួលបានតាមអ្វីដែលអ្នកធ្វើ។»

តើអ្វីខ្លះជាអត្តចរិតនៃសិស្សក្នុងបរិបទរបស់អ្នក ហើយតើអ្នកនឹងពន្យល់អត្ថន័យនៃការបង្កើតសិស្ស យ៉ាងដូចម្តេច?

---

[5] The *General Rule of Discipleship* is an adaptation of Wesley's *General Rules*. (The Book of Discipline of The United Methodist Church—2012, ¶ 1117.2)

# អត្តចរិកនៃប្រព័ន្ធនៃការបង្កើតសិស្ស ដោយចេតនា

បន្ទាប់មក គ្រប់ទាំងប្រពន្ធ័បង្កើតសិស្សដោយចេតនា គួរមានចំណុចខាងក្រោមៈ

អត្តចរិករបស់សិស្សៈ បង្កើតការពិពណ៌នា ថាតើសិស្សមានលក្ខណៈ និង ដំណាក់កាលនៃការ រីកចំរើនយ៉ាងដូចម្តេចខ្លះ

អត្តចរិករបស់សិស្សពេញវ័យៈ តើអ្វីទៅជាលទ្ធផលចុងក្រោយរបស់ប្រពន្ធ័

ដំណាក់កាលរីកចំរើនរបស់ប្រពន្ធ័ៈ តើសិស្សរីកចំរើនបែបណា?

ដើម្បីបង្ហាញធាតុសំខាន់ៗនៃប្រពន្ធ័បង្កើតសិស្សដោយចេតនា ខ្ញុំប្រើតារាង ដែលខ្ញុំដកស្រង់ ចេញពីសៀវភៅរបស់លោក Phil Maynard, ដែលជាអ្នកបង្កើត EMC3 Coaching និងជាអ្នកនិពន្ធ សៀវភៅទាក់ទងនិងការបង្កើតសិស្ស ដូចជាសៀវភៅ *Shift: Helping Congregations Back Into the Game of Effective Ministry*, និង *Membership to Discipleship: Growing Mature Disciples Who Make Disciples* (See Figure B).

## អត្តចរិករបស់សិស្ស (ក្រឡានខាងឆ្វេង)

ក្រឡាននេះ អ្នកនិងសរសេរចុះពីអត្តចរិកនៃសិស្សដែលពន្ធ័កិច្ចរបស់អ្នកនឹងផ្តោតទៅលើ ជាការសំខាន់សំរាប់ការរីកចំរើនរបស់សិស្ស។ យើងសូមប្រាប់ពីអត្តចរិក ជាឧទាហរណ៍ៈ

សិស្សថ្វាយបង្គំ
ជាផ្នែកមួយនៃសហគមន៍
មានការអនុវត្តន៍ផ្នែក ព្រលឹងវិញ្ញាណ
មានចិត្តល្អ និងបំរើ
ចង់ដូចជាព្រះគ្រីស្ទ

ក្នុងបរិបទរបស់អ្នក អ្នកអាចសំរេចចិត្ត ប្រើវិធីផ្សេងៗ លើអត្តចរិកទាំងនេះ ដែលស៊ីនឹងភាសា ដែលអ្នកប្រើក្នុងពន្ធ័កិច្ច និងបង្កើតមានសិស្សពេញវ័យដែលអ្នកចង់ឲ្យកើតមានក្នុងប្រពន្ធ័របស់អ្នក។

## អត្តចរិករបស់សិស្សដែលពេញវ័យ (ក្រឡោនខាងស្តាំ)

គ្រប់ទាំងអត្តចរិករបស់សិស្សដែលមានចៃក្នុងក្រឡោនខាងឆ្វេង សូមបង្កើតភាសាដែលរៀបរាប់ពីលទ្ធផលដែលយើងសង្ឃឹមថានឹងទទួលបាន តាមរយៈប្រពន្ធ័បង្កើតសិស្សរបស់យើង។ តើសិស្សដែលពេញវ័យនឹងមានលក្ខណៈយ៉ាងម៉េច?

**ការថ្វាយបង្គំ** – សិស្សពេញវ័យចាប់ផ្តើមថ្វាយបង្គំរាល់ថ្ងៃ រាប់ទាំងថ្ងៃបរិសុទ្ធ ហើយអញ្ជើញអ្នកដទៃ។

**សហគមន៍** – សាងទំនាក់ទំនងជាមួយអ្នកដទៃ ហើយប្រាប់ពួកគេពីជីវិត និងសហគមន៍ ដែលពួកគេមានក្នុងព្រះ និងសហគមន៍នៃសេចក្តីជំនឿ។

**ការអនុវត្តផ្នែកវិញ្ញាណ** – ចូលចិត្ត និងអនុវត្តន៍គោលការណ៍ព្រលឹងវិញ្ញាណ ហើយចាប់ផ្តើមបង្ហាញអ្នកដទៃ ពីការរីកចំរើនខាងសេចក្តីជំនឿ ហើយឲ្យមានភាពជិតស្និទ្ធជាមួយព្រះ

**ចិត្តសប្បុរស និងការបំរើ** – ការថ្វាយ១០ហូត១ និងថ្វាយលើស១០ហូត១ តាមព្រះដឹកនាំ ហើយរៀបចំជីវិត និងធនធាន ដើម្បីចូលរួមជាមួយព្រះយេស៊ូវ ក្នុងការបំរើអ្នកដទៃ។

**មានលក្ខណៈដូចព្រះគ្រីស្ទ** – សហការណ៍ជាមួយព្រះ ហើយអញ្ជើញអ្នកដទៃឲ្យស្វែងរកជីវិត និងការបង្រៀនរបស់ព្រះគ្រីស្ទ។

## ដំណាក់កាលនៃការរីកចំរើន (ខាងលើតារាង)

ខាងលើតារាង មានបញ្ជីនៃដំណាក់កាលនៃការរីកចំរើន ដែលសហគមន៍របស់អ្នកនឹងស្គាល់។ ឧទាហរណ៍ យើងប្រើ៖ ការស្រាវជ្រាវ ការស្វែងរក ការចាប់ផ្តើម ការរីកចំរើន និងការពេញវ័យ។ ឧទាហរណ៍មួយទៀតគឺ៖ ការជឿ ការប្រព្រឹត្ត ការចូលរួមទទួលខុសត្រូវ។ ហើយយើងពន្យល់ចំនុចនិមួយៗដូច្នេះ៖

**ការស្រាវជ្រាវ** – ស្រាវជ្រាវពីអត្ថន័យជីវិត៖ សួរសំនួរដូចជា «តើអ្វីទៅដែលផ្តល់ជាគោលបំណង សេចក្តីអំណរ និងការស្កប់ស្កល់ សំរាប់ជីវិតខ្ញុំ?»

**ការស្វែងរក** – ចូលរួម តែមិនទទួលខុសត្រូវ។ ប្រហែលជាមិនទាន់ដាក់ចិត្តដើរតាមព្រះយេស៊ូវ។ កំពុងប្រទាញប្រទង់ជាមួយវត្តមានព្រះក្នុងជីវិតរបស់គេ។

**ការចាប់ផ្តើម** – ចាប់ផ្តើមយល់ ហើយអនុវត្តសេចក្តីជំនឿដែលគេទើបរកឃើញ។ រំភើបចំពោះសេចក្តីជំនឿ តែនៅមានចម្ងល់។

**រីកចំរើន** – ចង់ឲ្យគេដឹងថាខ្លួនជាអ្នកដើរតាមព្រះគ្រីស្ទ។ ទទួលការខុសត្រូវចំពោះខ្លួនឯងក្នុងការរីកចំរើនទំនាក់ទំនងជាមួយព្រះយេស៊ូវ។ ចាប់ផ្តើមបញ្ចូលសេចក្តីជំនឿក្នុងជីវិត និងស្វែងរកជំនួយពីព្រះយេស៊ូវ។

**ពេញវ័យ** – ថ្វាយជីវិតរបស់យើងដល់ព្រះយេស៊ូវ។ ចង់ដឹង ស្រឡាញ់ គោរពបំរើ និងនៅជាមួយព្រះយេស៊ូវ ជាសិស្សទ្រង់ ហើយចាប់ផ្តើមបង្កើតសិស្ស។

# ចំណាយពេលបន្តិច៖

**ចំណាយពេលធ្វើឲ្យគោលការណ៍នៃប្រពន្ធ័បង្កើតសិស្សនេះ ក្លាយជារបស់អ្នក៖**

1. តើដំណាក់កាលនៃការរីកចំរើនរបស់អ្នក មានលក្ខណៈយ៉ាងម៉េច?

2. តើអ្វីទៅជានិយមន័យនៃការបង្កើតសិស្សក្នុងបរិបទរបស់អ្នក?

3. តើអ្វីជាក្តីសង្ឃឹមនៃលទ្ធផលចុងក្រោយ នៃសិស្សដែលមានភាពពេញវ័យ ក្នុងបរិបទពន្ធ័កិច្ច របស់អ្នក?

តារាង B

# គំរូប្រព័ន្ធបង្កើតសិស្ស (សម្រួលតាមតារាងរបស់លោក Phil Maynard)

| | ស្រាវជ្រាវ | ស្វែងរក | ចាប់ផ្ដើម | រីកចំរើន | ពេញវ័យ |
|---|---|---|---|---|---|
| **ថ្វាយបង្គំ** | ស្រាវជ្រាវរកអ្វីបន្ថែម | មិត្តភក្ដិអញ្ជើញ មកចូលរួមថ្វាយបង្គំ។ ចូលរួមយូរៗម្ដង។ | ចាប់ផ្ដើមថ្វាយបង្គំ ទាងទាត់ ដឹងពីវត្តមានព្រះរាល់ថ្ងៃ។ | ចូលរួមទាងទាត់ ហើយស្គាល់ពីចលនានៃការថ្វាយបង្គំរាល់ថ្ងៃ។ | ចាប់ផ្ដើមឲ្យតំលៃ និងការថ្វាយបង្គំក្នុងការងាររាល់ថ្ងៃ។ អញ្ជើញអ្នកដទៃមកថ្វាយបង្គំ។ |
| **សហគមន៍** | ស្វែងរកសហគមន៍ល្អមួយ | ចាប់ផ្ដើមចូលចិត្តអ្នកដើរតាមព្រះយេស៊ូវ ហើយមានការកក់ក្ដៅទទួលគេទាំងនោះ។ | ឈប់ទទួលភាពចៅរ៉ៅ ទៅជាផ្ដល់ភាពចៅរ៉ៅដល់អ្នកដទៃ។ | ចាប់ផ្ដើមរកមើលវិធីបង្ហាញសេចក្ដីស្រឡាញ់ និងមានទំនាក់ទំនងជាមួយអ្នកដទៃដូចជាអ្វីដែលក្រុមជំនុំធ្លាប់បានធ្វើមកអ្នក។ | សាងសង់ទំនាក់ទំនងជាមួយអ្នកដទៃ ហើយចែករំលែកពីជីវិតដែលអ្នកមានក្នុងសហគមន៍ និងជាមួយព្រះ។ |
| **អនុវត្តន៍ផ្នែកវិញ្ញាណ** | ឆ្ងល់ពីព្រះគម្ពីរ និងចង់ដឹងពីវិធីទំនាក់ទំនងជាមួយព្រះ។ | ចាប់អារម្មណ៍ចំពោះរឿងសេចក្ដីស្រឡាញ់របស់ព្រះ និងចាប់ផ្ដើមយល់ដឹងពីព្រះគម្ពីរ។ | ចាប់ផ្ដើមអធិស្ឋាន និងអានព្រះគម្ពីរទាងទាត់ ដោយបើកចំហរជាមួយព្រះ។ | ចាប់ផ្ដើមអនុវត្តន៍គោលការណ៍ផ្នែកវិញ្ញាណ មានទំនាក់ទំនងជាមួយព្រះ រាល់ថ្ងៃ។ | ចូលចិត្តការអនុវត្តន៍ផ្នែកវិញ្ញាណ ហើយចាប់ផ្ដើមប្រាប់អ្នកដទៃពីការអនុវត្តន៍នេះ ដើម្បីរីកចំរើនផ្នែកវិញ្ញាណ |
| **សប្បុរស និងការបំរើ** | ឆ្ងល់ថាតើមានអ្វីច្រើនជាង ការរកលុយ និងការរកប្រយោជន៍ខ្លួនឯង | ដាក់ដង្វាយម្ដងម្កាល ហើយចូលរួមការងារក្រុមជំនុំ។ ឃើញអ្នកដទៃជួយឲ្យជីវិតអ្នកដទៃមានការផ្លាស់ប្រែ ហើយចង់ចូលរួមដែរ។ | ថ្វាយដង្វាយ និងពេលវេលាទៀងទាត់។ យល់ពីការត្រាស់ហៅរបស់ព្រះគ្រីស្ទ ហើយដឹងពីអំណោយទានដែលព្រះប្រទានឲ្យអ្នក។ | ដាក់ដង្វាយជាធនធាន ពេលវេលា និងជំនាញ ចំពោះព្រះ តាមរយៈពន្ធកិច្ចក្រុមជំនុំ។ រកវិធីប្រើប្រាស់ធនធាន ពេលវេលា និងជំនាញ។ | ដាក់ដង្វាយដប់ហូតមួយ ហើយជូនកាលថ្វាយលើសទៀត ហើយចាប់ផ្ដើមធ្វើជីវិតទៅតាមបេសកកម្មរបស់ព្រះយេស៊ូវ។ |
| **ភាពដូចព្រះគ្រីស្ទ** | ជីវិត និងមេរៀន របស់ព្រះយេស៊ូវគួរឲ្យចូលចិត្ត។ | ស្វែងយល់ពីជីវិតរបស់ព្រះគ្រីស្ទដោយខ្លួនឯង ដោយការអានព្រះគម្ពីរ | ទទួលការត្រាស់ហៅរបស់ព្រះ ហើយចូលរួមជាមួយក្រុមជំនុំ។ ចង់បំរើអ្នកដទៃ | យកមេរៀនរបស់ព្រះគ្រីស្ទអនុវត្តន៍ក្នុងជីវិត។ | សហការណ៍ជាមួយព្រះ ហើយអញ្ជើញអ្នកដទៃស្វែករកជីវិតក្នុងព្រះគ្រីស្ទ។ |

ព្រះគុណដំបូង | ព្រះគុណរាប់ជាបរិសុទ្ធ | ព្រះគុណញែកជាបរិសុទ្ធ

# គំនិតសំរាប់បង្កើតប្រព័ន្ធ នៃការបង្កើតសិស្ស ដោយចេតនារបស់អ្នក

ពេលដែលអ្នកយកប្រពន្ធ័ការបង្កើតសិស្សដោយចេតនា ទៅប្រើប្រាស់ក្នុងក្រុមជំនុំរបស់អ្នក នោះអ្នកនឹងបង្កើតប្រពន្ធ័បង្កើតសិស្សមួយ។ បើអ្នកដកចេញនូវការពិពណ៌នា នៃអត្តចរិតក្នុង ដំណាក់កាលនិមួយៗ នោះអ្នកនឹងទទួលបានតារាងនៃការបង្កើតសិស្សមួយ (សូមមើល តារាង C ខាងក្រោម)។ អ្នកដឹកនាំក្នុងក្រុមជំនុំរបស់អ្នក អាចចាប់ផ្តើមថាតើក្រុមជំនុំរបស់អ្នក នឹងធ្វើបែបណា ដើម្បីផ្តល់ឪកាសសំរាប់ពួកសិស្សរីកចំរើន និងពេញវ័យក្នុងសេចក្តីជំនឿ

### ការបង្កើតសិស្ស៖ ជាប្រពន្ធ័ និងរចនាសម្ពន្ធ័
(សម្រួលតាមតារាងរបស់លោក Phil Maynard)

| | ស្រាវជ្រាវ | ស្វែងរក | ចាប់ផ្តើម | រីកចំរើន | ពេញវ័យ |
|---|---|---|---|---|---|
| ថ្វាយបង្គំ | | | | | |
| សហគមន៍ | | | | | |
| អនុវត្តន៍ផ្នែកវិញ្ញាណ | | | | | |
| សប្បុរសធម៌ និងការបំរើ | | | | | |
| ភាពដូចព្រះគ្រីស្ទ | | | | | |
| | ព្រះគុណដំបូង | | ព្រះគុណរាប់ជាបរិសុទ្ធ | | ព្រះគុណញែកជាបរិសុទ្ធ |

តារាង C

# របៀបតាមបែបវេស្លី

ពេលយើងចាប់ផ្តើមបង្កើតប្រពន្ធ័បង្កើតសិស្សដោយចេតនា យើងត្រូវចាំថា យើងមានប្រពៃណីនៃការបង្កើតសិស្សដែលយើងអាចយកមកប្រើបាន។ ក្រុមជំនុំមេថូឌីស្ទពីដំបូង បង្កើតការជុំគ្នាជាថ្នាក់រៀន (Class meetings) ជួបគ្នាជាក្រុម (Band meetings) និងក្រុមជំរើស (select societies) (ប្រពន្ធ័ក្រុមតូចពីដើម និងឱកាសសំរាប់ការបង្កើតខាងវិញ្ញាណ) ដែលប្រពន្ធ័របស់គេណែនាំពួកសិស្សថ្មីៗ ពីសេចក្តីជំនឿ និងជួយឲ្យគេពេញវ័យ។ ក្នុងប្រពន្ធ័នេះ ពួកសិស្ស ត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងក្រុមតូច សំរាប់ពិភាក្សាគ្នាជាគ្រីស្ទបរិសទ្ធ និងអនុវត្តន៍វិធីនៃព្រះគុណ។

ក្នុងក្រុមតូចទាំងនេះ ពួកមេថូឌីស្ទត្រូវបានលើកទឹកចិត្តឲ្យធ្វើតាមច្បាប់ទូទៅរបស់លោកវេស្លី៖

1. កុំធ្វើឲ្យប៉ះពាល់អ្នកដទៃ ដោយចៀសវាងការអាក្រក់គ្រប់យ៉ាង។

2. ធ្វើល្អឲ្យបានញឹកញាប់ ដល់មនុស្សជាច្រើន (ចំពោះរូបកាយ និងវិញ្ញាណគេ។)

3. អនុវត្តន៍វិធីនៃព្រះគុណ ដែលព្រះយេស៊ូវបង្រៀនពួកសិស្ស។

## វិធីនៃព្រះគុណ

| ការងារមេត្តាករុណា | ការងារបរិសុទ្ធ |
|---|---|
| - ឲ្យអាហារអ្នកឃ្លាន | - ថ្វាយបង្គំជាសាធារណៈ |
| - ឲ្យសំលៀកបំពាក់ដល់អ្នកក្រ | - អានព្រះបន្ទូល |
| - ជួយមើលថែរអ្នកឈឺ | - ពិធីលៀងព្រះអម្ចាស់ |
| - សួរសុខទុក្ខអ្នកជាប់គុក | - អធិស្ឋានផ្ទាល់ខ្លួន&គ្រួសារ |
| - ផ្តល់ជំរកដល់អ្នកអត់ផ្ទះ | - សិក្សាព្រះគម្ពីរ |
| - ស្វាគមន៍មនុស្សចំឡែក | - តមអាហារ |
| - បង្កើតសន្តិភាព | - ប្រកបជាមួយគ្រីស្ទបរិសទ្ធ |
| - បំរើការល្អ | |

ដើម្បីទទួលបានធនធានផ្សេងទៀត ដែលទាក់ទងនិង Wesleyan Way សូមចុច៖
www.UMCdiscipleship.org/covenantdiscipleship

# ការបង្កើតសិស្ស និងការដឹកនាំផ្ទាល់ខ្លួន

ការផ្លាស់ប្តូរវប្បធម៌នៃក្រុមជំនុំរបស់អ្នក ដើម្បីបង្កើតសិស្សដោយចេតនា គឺចាប់ផ្តើមពីអ្នកដឹកនាំ។ គ្រប់ការទាំងអស់ វាឡើងឬចុះ ដោយសារអ្នកដឹកនាំ។ មានអ្នកដឹកនាំជាច្រើនដែលយល់ខុសថាភាពរស់ជាស្នាដៃ និងសកម្មភាពសំរាប់ជោគជ័យ។ យើងតែងយល់ខុសថា គោលដៅរបស់ក្រុមជំនុំដែលជោគជ័យ គឺជាការមានកម្មវិធីជាច្រើន៧ថ្ងៃក្នុងមួយសប្តាហ៍។ ការពិតនោះគឺថា ក្រុមជំនុំរបស់អ្នកអាចរស់ ហើយនៅតែមិនធ្វើការត្រឹមត្រូវ។

ការបង្កើតសិស្សដោយចេតនាចាប់ផ្តើម ពេលអ្នកដឹកនាំធ្វើជាគំរូក្នុងភាពជាសិស្សដែលរីកចំរើន និងពេញវ័យ។ ថ្នាក់ដឹកនាំគ្រប់កំរិត ត្រូវតែស្មោះត្រង់ ហើយអាចចែកចាយពីការដែលពួកគេរីក ចំរើនផ្នែកសេចក្តីជំនឿ ហើយលើកទឹកចិត្តគេក្នុងដំណើរសេចក្តីជំនឿ។ គ្រប់ក្រុមគួរប្រជុំគ្នា ជាឱកាសមិនមែនសំរាប់បំពេញការងាររដ្ឋបាល ប៉ុន្តែគឺដើម្បីផ្តល់ពេលលើកទឹកចិត្តក្នុងការ រីកចំរើនផ្នែកវិញ្ញាណ។ ដូចជាប្រពន្ធ័ថ្នាក់មេថូឌីស្ទដែរ គ្រប់ក្រុមត្រូវមានសកម្មភាពជាក្រុមតូច។

ការបង្កើតសិស្សដោយចេតនាគ្រប់កំរិតនៃអ្នកដឹកនាំ នឹងផ្តោតលើ គណៈកម្មការទំនាក់ទំនងក្រុមជំនុំ និងគ្រូគង្វាល និងគណៈកម្មការរើសតាំង និងការអភិវឌ្ឍន៍អ្នកដឹកនាំ។ ការផ្តោតលើការ អភិវឌ្ឍន៍ និងការរីកចំរើនក្នុងការបង្កើតសិស្សក្នុងចំណោមអ្នកដឹកនាំ មើលទៅដូចជាមិនអស្ចារ្យទេ តែវាជាម៉ាស៊ីនដែលធ្វើឲ្យក្រុមជំនុំរបស់យើងរីកចំរើន។ អ្នកដឹកនាំល្អ ធ្វើឲ្យក្រុមជំនុំរីកចំរើន។ ក្រុមជំនុំល្អបណ្តុះអ្នកដឹកនាំល្អ។ យើងត្រូវតែជាគំរូនៃការរីកចំរើនក្នុងការបង្កើតសិស្សក្នុងចំណោមអ្នកដឹកនាំ បើសិនជាយើងចង់ឃើញវាក្នុងក្រុមជំនុំរបស់យើង។

ការបង្កើតសិស្សដោយចេតនាត្រូវតែជាអទិភាពក្នុងក្រុមអ្នកដឹកនាំ។ យើងត្រូវតែផ្តោតលើការបង្កើតនិងការរីកចំរើន ជានិច្ច។ អ្នកដឹកនាំត្រូវតែយល់ច្បាស់ពីតួនាទីរបស់គេក្នុងការជួយមនុស្ស ឲ្យរីកចំរើន ផ្នែកព្រលឹងវិញ្ញាណ ក្នុងបរិបទក្រុមជំនុំ និងសហគមន៍។ បែបនេះ តួនាទីនៃអ្នកដឹកនាំ គឺផ្លាស់ប្រែពី «ជួសជុលក្រុមជំនុំ» ទៅជាការសាងអណាចក្រព្រះ។ ការផ្តោតអារម្មណ៍របស់យើង បែរចេញពីការធ្វើឲ្យក្រុមជំនុំកាន់តែធំ ទៅជាការបង្កើតសិស្សឲ្យកាន់តែច្រើន។

# ចំណាយពេលបន្តិច

1. តើការផ្តោតលើការបង្កើតសិស្សដោយចេតនាផ្លាស់ប្តូរការដឹកនាំរបស់ក្រុមជំនុំរបស់អ្នកយ៉ាងណា?

2. តើការផ្តោតលើការបង្កើតសិស្សដោយចេតនាប្តូរទិសដៅនៃគណៈកម្មការទំនាក់ទំនងគ្រូគង្វាល និងក្រុមជំនុំ និងគណៈកម្មការជ្រើសតាំងអ្នកដឹកនាំយ៉ាងណាដែរ?

# ការឃើញ&ការឈោងចាប់មនុស្សគ្រប់គ្នា

## ហោណាំងមុខផ្ទះធំ

ពេលយើងមើលបញ្ហាបច្ចុប្បន្ន និងពេលអនាគត នៃការបង្កើតសិស្សក្នុងសតវត្សទី២១ ខ្ញុំឃើញពីសេចក្ដីត្រូវការកាន់តែច្រើនរបស់ក្រុមជំនុំក្នុងការយល់ពីហោណាំងមុខផ្ទះ។ អ្វីដែលខ្ញុំចង់និយាយនោះគឺការបង្កើតដោយចេតនាក្នុងផ្នែកខាងមុខនៃប្រព័ន្ធបង្កើតសិស្ស។ បើអ្នក គិតស្របជាមួយកំរិតនៃការរីកចំរើន ខ្ញុំគិតអំពីឱកាសដែលយើងផ្ដល់ឲ្យ ក្នុងតំបន់នៃការស្រាវជ្រាវ និងការស្វែងរក។ តើក្រុមជំនុំរបស់អ្នកអាចធ្វើយ៉ាងម៉េចឲ្យកាន់តែមានចេតនា ទាក់ទងនិងការបង្កើតកន្លែង និងឱកាស សំរាប់អ្នកដែលកំពុងស្រាវជ្រាវសំរាប់អត្ថន័យផ្នែកវិញ្ញាណ ក្នុងជីវិត ឬការស្វែងរកជីវិតជាគ្រីស្ទបរិសទ្ធ។ តើអ្នកជួយអ្នកដឹកនាំ ឲ្យយល់ពីសារៈសំខាន់ នៃការបង្កើតតំបន់យ៉ាងនេះ ហើយបង្រៀនពួកគេពីវិធីល្អៗ ក្នុងការទាក់ទងជាមួយអ្នកដែលកំពុងស្រាវជ្រាវ និងអ្នកដែលស្វែងរក។

យើងដឹងហើយថា និកាយរបស់យើងបានធ្វើការនេះ ដោយវិធីផ្សេងៗ។ Fresh Expressions គឺជាឧទាហរណ៍មួយសំរាប់ក្រុមជំនុំដែលបង្កើតកន្លែងសុវត្ថិភាព សំរាប់អ្នកដែលមិនដែលមកព្រះវិហារដើម្បីឲ្យពួកគេអាចមានទំលាប់មកព្រះវិហារ។ វិធីទាំងអស់នេះ ភាគច្រើនទាក់ទងនិងបែបផែនជីវិត និងចំណង់ចំណូលចិត្ត ដូចជា Skateboarding, surfing, rock climbing, ។ល។ ហើយយើងក៏អាច ភ្ជាប់ជាមួយតន្ត្រី និងកាហ្វេ។

ពេលដែលក្រុមជំនុំចាប់ផ្ដើមបង្កើតឱកាស និងបទពិសោធន៍ទាំងនេះ សូមកុំឲ្យចេតនារបស់យើង សាបរលត់ឡើយ។ បើអ្នកបង្កើតហាងកាហ្វេ ឬ កន្លែងជិះ Skateboard ដែលមិនដែលមានឱកាស ក្នុងការអញ្ជើញពួកគេឲ្យមានទំនាក់ទំនងជាមួយសហគមន៍យើង ឬមិនដែលមានឱកាសបង្កើតសិស្ស ជាមួយគេ នោះអ្នកគ្រាន់តែជួយអ្នកផឹកកាហ្វេ និងអ្នកជិះ Skateboard តែប៉ុណ្ណោះ។ អ្នកត្រូវតែបង្កើតជាសហគមន៍ ជាមួយឱកាសក្នុងការណែនាំនៃការបង្កើតសិស្សដំបូង។ ក្នុងការបង្កើត ហោរណាំងធំមុខផ្ទះ សូមចាប់ផ្ដើមស្វែងរកវិធីរបស់ព្រះយេស៊ូវ តើអ្នកនឹងជួយជំហ៊ានបន្ទាប់ យ៉ាងម៉េច? តើធ្វើម៉េច ទើបអ្នកអាចជួយអ្នកស្វែងរក ឲ្យក្លាយជាអ្នកចាប់ផ្ដើម? ជាមួយគ្នានេះដែរ សូមកុំឲ្យហោណាំងធំមុខផ្ទះ បាត់សោះឡើយ ដោយសារមានមនុស្សជាច្រើននឹងក្លាយជាអ្នកដើរតាមព្រះយេស៊ូវ។ បើការនេះ

កើតឡើង នោះអ្នកនឹងមាន ហាងកាហ្វេគ្រីស្ទបរិសទ្ធ ឬក្លិបគ្រីស្ទានអ្នកជិះ Skateboard។ កន្លែងនិងឱកាសដែលអ្នកបានបង្កើត សំរាប់អ្នកដែលស្រាវជ្រាវ និងស្វែងរក និងត្រូវបន្តសំរាប់អ្នកថ្មីទៀត។ តាមរយៈប្រព័ន្ធ ហោណាំងធំមុខផ្ទះ ក្រុមជំនុំរបស់អ្នកត្រូវតែមានចេតនាអំពីការបន្តផ្តល់កន្លែងសុវត្ថិភាពសំរាប់ អ្នកស្រាវជ្រាវរកអត្ថន័យព្រលឹងវិញ្ញាណ និងស្វែងរកជីវិតជាគ្រីស្ទបរិសទ្ធ។

# អ្វីទាំងអស់គឺទាក់ទងនិងទំនាក់ទំនង

## ការផ្សារផ្ជាប់ និងទំនាក់ទំនង បេសកកម្ម

ខ្ញុំប្រើពាក្យផ្សារផ្ជាប់ ដើម្បីផ្ទុយពីពាក្យ «ឈោងចាប់» ដែលយើងធ្លាប់ប្រើ។ ខ្ញុំសូមពន្យល់ការខុសគ្នា។ ការឈោងចាប់មានទំរង់ពីរ។ វាអាចជាផ្នែកបេសកកម្ម។ នេះជាព័ន្ធកិច្ចដែលជួយ ដូចជាចែកអាហារ សំលៀកបំពាក់ សំអាតទីធ្លាសហាគមន៍ ។ល។ មានការឈោងចាប់មួយចំនួនទៀត ដែលមានការផ្សាយដំណឹងល្អ។ សកម្មភាពដូចជា ការធ្វើពិធីតាមផ្លូវថ្នល់ និងការដើរចែកលិខិតអញ្ជើញមកព្រះវិហារថ្ងៃអាទិត្យ ឬយើងទៅតាមសួនច្បារដើម្បីចែកទឹក ដោយមាន ពត៌មានក្រុមជំនុំយើងក្នុងនោះ។ ខ្ញុំគិតថាព័ន្ធកិច្ចដែលគ្រាន់តែអញ្ជើញមនុស្សមកក្រុមជំនុំ ដោយមិនមានទំនាក់ទំនង នោះមិនគ្រប់គ្រាន់ទេ។ វាខ្វះចំនុចនៃការបង្កើតសិស្ស ដោយចេតនា។ ការផ្សារផ្ជាប់បេសកកម្ម គឺជាការកសាងទំនាក់ទំនងយូរអង្វែង និងស្មោះត្រង់។ ទំនាក់ទំនងដែលមានអត្តចរិកទាំងបីនេះ នឹងនាំឲ្យមានការបង្កើត សិស្សដោយចេតនា។

**ពិតប្រាកដ (Authenic)**៖ វចនានុក្រម Merriam-Webster ពន្យល់ថា «ភាពដើមដែលមិនអាចប្រកែកបាន»។ តើការផ្សារភ្ជាប់បេសកកម្មជាមួយអ្នកដទៃរបស់យើងមានភាពពិតប្រាកដទេ? តើវាចេញពីកន្លែងល្អទេ? តើវាមានប្រភពល្អទេ ? ពេលយើងរីកចំរើនផ្នែកសេចក្តីជំនឿ ជាសិស្សរបស់ព្រះយេស៊ូវ នោះយើងគួរមិនគិតតែពីខ្លួនឯង មានការយកចិត្តទុកដាក់ចំពោះពិភពលោកជុំវិញខ្លួនយើង។ ការយកចិត្តទុកដាក់នេះ គួរបើកសំដែងក្នុង ទំនាក់ទំនងរបស់យើង។ ពេលយើង ទំនាក់ទំនងជាមួយអ្នកដែលនៅក្រៅក្រុមជំនុំ វាសំខាន់ណាស់ដែលយើងត្រូវច្បាស់ថា យើងមានគោលបំណងពិតប្រាកដ។ ការដែលយើងមានភាពពិតប្រាកដ និង ស្មោះត្រង់ នោះយើងអាចចែកចាយសេចក្តីជំនឿរបស់យើងកាន់តែល្អ។

**សរីរាង្គ (Organic)**៖ ពេលយើងផ្សារភ្ជាប់ជាមួយអ្នកដទៃ ហើយចាប់ផ្តើមសាងទំនាក់ទំនង វាត្រូវតែសរីរាង្គ យើងមិនអាចបង្ខំវាបានទេ។ សូមគិតថា ពាក្យសរីរាង្គនិយាយពីរុក្ខជាតិដែល លូតលាស់តាមបែបធម្មជាតិ។ គ្រូគង្វាលក្មេងម្នាក់ប្រាប់ខ្ញុំថា គាត់និងប្រពន្ធរបស់គាត់សំរេចចិត្តមិនប្រើទូរទស្សន៍ខ្សែរកាប ព្រោះគាត់ចង់សន្សំលុយ។ ធ្វើអញ្ចឹង គាត់មិនអាចមើលកីឡាបាល់ទាត់ បន្ទាប់ពីកម្មវិធីថ្វាយបង្គំ

ថ្ងៃអាទិត្យ ដូច្នេះគាត់ទៅបារក្នុងភូមិដើម្បីមើលបាល់។ បីបួនសប្តាហ៍កន្លងមក មានការមួយកើតឡើង។ គាត់បានបង្កើតមិត្តភាពជាមួយមនុស្សជាច្រើនដែលទៅមើលបាល់នៅបារនោះ។ បន្ទាប់មក ទំនាក់ទំនងនេះកាន់តែល្អទៅ គាត់មានឱកាសចែកចាយពីសេចក្តីជំនឿរបស់គាត់។ ការសន្ទនានេះ នាំមនុស្សបីបួននាក់ទទួលជឿព្រះ យេស៊ូវជាព្រះសង្គ្រោះ ហើយពួកគេចាប់ផ្តើមមកព្រះវិហារ។

**មិនផ្លាស់ប្តូរ (Consistent)៖** ទំនាក់ទំនងល្អទាមទារពេលវេលាមិនផ្លាស់ប្តូរ។ មិនផ្លាស់ប្តូរ មានន័យថា ទំនាក់ទំនងរបស់យើងមិនមែនជាការផ្លាស់ប្តូរទំនិញទេ។ យើងមិនមែនគ្រាន់តែចង់ឲ្យគេមកក្រុមជំនុំនោះទេ។ យើងចង់ស្គាល់គេ ហើយចង់មានទំនាក់ទំនងល្អជាមួយអ្នកជិតខាង ទោះជាគេមិនទៅព្រះវិហារក៏ដោយ។ ទំនាក់ទំនងមិនផ្លាស់ប្តូរ មានដូចជាការទូរសព្ទរកគ្នា ការអញ្ជើញចូលរួមកក្នុងកម្មវិធីផ្សេងៗ ឬយើងអាចប្រាប់គាត់ថា ក្រុមជំនុំរបស់យើងបានអធិស្ឋានជូនគេ។ អ្នកនឹងរំភើបពេលឃើញអ្នកជិតខាងរបស់អ្នកក្លាយជាអ្នកគាំទ្រពន្ធកិច្ចក្រុមជំនុំ ទោះជាគេទៅថ្វាយបង្គំនៅព្រះវិហារផ្សេងក៏ដោយ។

ពេលទំនាក់ទំនងរបស់យើងពិតប្រាកដ សរីរាង្គ និងមិនផ្លាស់ប្តូរ នោះយើងបង្កើតកន្លែងសំរាប់ ការចែកចាយសេចក្តីជំនឿ។ ទំនាក់ទំនង មិនមែនជាកម្មវិធីទេ វាគឺជាឥរិយាបទដែល ចាក់ឫសក្នុងក្រុមជំនុំដែលយល់ពីការបង្កើតសិស្សដោយចេតនា។ ឥរិយាបទនេះក៏អាចកែប្រែការដែលក្រុមជំនុំរៀបចំកម្មវិធីផ្សេងៗ។ សូមគិតពីកម្មវិធីឈោងចាប់ ដែលក្រុមជំនុំរបស់អ្នក ធ្វើជារឿយៗ។ ឧទាហរណ៍ថា កម្មវិធីរើសពងថ្ងៃEaster ឬកម្មវិធី ចែកសំលៀកបំពាក់។ តើកម្មវិធីនេះ នឹងមានការផ្លាស់ប្តូរអ្វីខ្លះ បើយើងរៀបចំដើម្បីធ្វើយ៉ាងណា ឲ្យការទំនាក់ទំនងរបស់យើង ជាមួយអ្នកដទៃ វាពិតប្រាកដ សរីរាង្គ និងមិនផ្លាស់ប្តូរ? យើងអាចរៀបជាក្រុមមួយ ដែលមានតួនាទីនិយាយជាមួយអ្នកដទៃ និងស្តាប់រឿងរបស់គេ។ យើងមិនអាចបង្កើតសិស្ស ដោយគ្មានការទំនាក់ទំនងជាមួយមនុស្សបានទេ។

ចុងក្រោយ សូមគិតថាតើអ្នកអាចធ្វើឲ្យបច្ចេកវិទ្យាក្នុងព័ន្ធកិច្ចរបស់អ្នកកាន់តែល្អ ដើម្បីអាច បង្កើនទំនាក់ទំនង នៅថ្ងៃខាងមុខ។ តើអ្នកអាចមានការសន្ទនា និងទំនាក់ទំនង តាមរយៈ គេហទំព័រ បណ្តាញសង្គម blog វីដេអូ ឬ podcasts តាមរបៀបណា? តើយើងអាចផ្សារផ្ជាប់មនុស្សដែលនៅក្រៅក្រុមជំនុំរបស់យើង ដោយវិជ្ជមាន ដែលយើងអាចជួបគេ ហើយយល់ពីសេចក្តីត្រូវការផ្នែកព្រលឹងវិញ្ញាណរបស់គេ។ បង្កើតកន្លែងសំរាប់ការសន្ទនា ដែលអាចនាំមកនូវទំនាក់ទំនងថ្មី។ តែសូមកុំភ្លេច បច្ចេកវិទ្យា មិនអាចជំនួស ការទំនាក់ទំនងមុខទល់និងមុខបានទេ តែវាអាចជាចំនុចចាប់ផ្តើម។

ការបង្កើតសិស្សចាប់ផ្តើមពីទំនាក់ទំនង ពិតប្រាកដ សរីរាង្គ និងមិនផ្លាស់ប្តូរ

«យើងមិនអាចប
ង្កើតសិស្សដោយ
គ្មានទំនាក់ទំនង
ជាមួយមនុស្ស
បានទេ។»

# ការបង្កើតសិស្ស ដោយចេតនា ក្នុងនិកាយទាំងមូល

ចលនានៃការបង្កើតសិស្សដោយចេតនាកើតឡើងក្នុងនិកាយទាំងមូល។ អ្នកដឹកនាំ និងក្រុមជំនុំជាច្រើនចាប់ផ្តើមទទួលស្គាល់ថា យើងត្រូវតែផ្តោតលើការបង្កើតសិស្ស ហើយចៀសចេញពីការជួសជុលក្រុមជំនុំ។ ខាងក្រោមនេះ ជាឧទាហរណ៍ មួយចំនួន។ អ្នករកឃើញឧទាហរណ៍ជាច្រើនទៀតក្នុង UMCdiscipleship.org.

## ការបង្កើតសិស្សដោយចេតនាក្នុងក្រុមតូច

**ក្រុមជំនុំ Broomfield United Methodist Church, Colorado**

សមាជិកនៃ Broomfield United Methodist Church, មានទីតាំងចន្លោះ ទីក្រុងDenver និងទីក្រុង Boulder ក្នុងរដ្ឋ Colorado, មានភាពសកម្មក្នុងក្រុមតូច ផ្សេងៗ។ តាមការស្រាវជ្រាវរបស់ក្រុមជំនុំក្នុងឆ្នាំ២០០៤ត២០០៥ សមាជិក និង អ្នកដឹកនាំ នៃBUMC ទទួលស្គាល់ពីសារៈសំខាន់នៃក្រុមតូចដែលជាផ្នែកសំខាន់ មួយនៃប្រពន្ធបង្កើតសិស្សដោយចេតនា។ បេសកកម្ម របស់ក្រុមជំនុំ--ថ្វាយបង្គំព្រះ រីកចំរើនជាមួយព្រះ ប្រាប់អ្នកដទៃពីព្រះ--បើកសម្តែងក្នុងអទិភាព ដូចខាងក្រោម៖ ព្រះគម្ពីរ ការថ្វាយបង្គំ ការប្រកបក្រុមតូច ឈោងចាប់ពីភពលោក និងព័ន្ធកិច្ច របស់ គ្រូគង្វាល និងក្រុមជំនុំ។ ក្រុមបង្កើតសិស្សស្នូល មានបួនក្រុម ដែលជួបគ្នាព្រឹក ថ្ងៃអាទិត្យ ក្រុមបុរសចំនួន៦ ក្រុមរៀនព្រះគម្ពីរស្ត្រីចំនួន៤ និងក្រុមរៀនគម្ពីរ ពេលល្ងាចមួយចំនួនទៀត។ ក្រុមអ្នកជិតខាងបីក្រុម និងក្រុមស្ត្រីមេថូឌីស្ទចំនួន៦។ ក្រុមទាំងនេះផ្តល់ការសិក្សារផ្សេងៗ ការរីកចំរើនផ្នែកវិញ្ញាណ និងការគាំទ្រគ្នា ទៅវិញទៅមក។ ក្រុមទាំងនេះភាគច្រើនមានការសិក្សារ ព្រះគម្ពីរ ការសិក្សារតាម ប្រធានបទ   ឬការរៀនតាមសៀវភៅ។

ជាងនេះទៅទៀត អ្នកដឹកនាំក្រុមតូច បង្កើតក្រុមតូចដែលមានគោលដៅតែមួយ រាល់ឆ្នាំ ដើម្បីបំពេញសេចក្តីត្រូវការពិសេសៗ។ ក្រុមភាគច្រើនគឺមានរយៈពេលខ្លី តែក្រុមខ្លះបន្តរហូត ដោយសារសមាជិកក្រុមមានទំនាក់ទំនងគ្នា។ ក្រុមតូចដែល

នៅបន្តដូចជា The Artist's Way, Just 10 LBS (ក្រុមស្រកគីឡូ), ឪពុកម្តាយក្មេងជំទង់ និង ក្រុមឪពុកម្តាយកូនពេញវ័យ។ BUMC មានក្រុមផ្សេងទៀតជាច្រើនឆ្នាំមកហើយដូចជា Alcoholics Anonymous, a Caregiver Group, Grief Support Groups, and an Autism Group. ក្រុមទាំងនេះ បានបង្កើតឡើងសំរាប់សេចក្តីត្រូវការ ហើយនិងបន្តដំណើររហូត ឲ្យតែក្រុមជំនុំត្រូវការ។ ក្រុមតូចដទៃទៀត ដូចជាក្រុមអ្នកនៅលីវ អ្នកកីឡា និងក្រុមអាហារពេលល្ងាច គឺជាក្រុមទំនាក់ទំនងសង្គម ដែលសមាជិកក្រុមអាចបង្កើតមិត្តភាពជាមួយគ្នា។ មានក្រុមផ្សេងទៀត ដូចជា the Prayer Shawl Ministry និងក្រុមសួរសុខទុក្ខ ដែលមានគោលបំណងចង់ បំរើអ្នកដទៃ។ ជាងនេះទៅទៀត លោក Thomas Cross ដែលជាគ្រូគង្វាល ខាងបង្កើតសិស្ស បង្រៀនថ្នាក់ខ្លីៗអំពី ទេវសាស្ត្ររបស់លោកវេស្លី និងប្រវត្តិគ្រីស្ទាន។ ថ្នាក់ទាំងនេះរួមមានគោលជំនឿរបស់ United Methodist, ច្បាប់គោលទាំងបី, ចំនុចសំគាល់ទាំង៥របស់មេថូឌីស្ទ, រឿងនាៗក្នុងព្រះគម្ពីរ, វចនានុក្រមនៃព្រះនៃសេចក្តីស្រឡាញ់ និងសិក្ខាសាលាព្រះវិញ្ញាណបរិសុទ្ធ។

ជាងនេះទៅទៀត គ្រូគង្វាលជ្រើសរើសការសិក្សារសំរាប់រដូវ Lent ជារាងរាល់ឆ្នាំដែលការអធិប្បាយក៏ត្រូវគ្នានិងការសិក្សារព្រះគម្ពីរដែរ។ លើសពីនេះទៀតគ្រូគង្វាលក៏ប្រាប់ពីបទគម្ពីរដែលសមាជិកអាចអានបាន។ ក្រុមសិក្សាព្រះគម្ពីរតាមរដូវកាល តែងតែប្រមូលផ្តុំគ្នាដើម្បីសិក្សារវគ្គខ្លី និងការសិក្សារដូវ Advent ក្នុងខែវិច្ឆិការ និងខែធ្នូ។ ការសិក្សារវគ្គខ្លីទាំងនេះ ទាក់ទាញមនុស្សចូលក្នុងក្រុមតូច ហើយអ្នកខ្លះទៀតក៏បន្តរៀនរហូតមក។

ដើម្បីជួយអ្នកមកថ្មីឲ្យចូលរួម គ្រូគង្វាល និងបុគ្គលិក មានកម្មវិធីពិសារ Pizza ជាមួយគ្រូគង្វាល ដែលជាឪកាសឲ្យបុគ្គលិកស្គាល់អ្នកមកថ្មី ហើយអាចប្រាប់គេពីព័ន្ធកិច្ច និងក្រុមតូចដែលមានក្នុងក្រុមជំនុំ។ បុគ្គលិកអញ្ជើញអ្នកដែលមកចូលរួមឲ្យបង្ហាញពីការចាប់អារម្មណ៍និងបទពិសោធន៍របស់គេ។ គ្រូគង្វៀលនៃការបង្កើតសិស្ស អញ្ជើញអស់អ្នកដែលមកពិសារ Pizza ជាមួយគ្រូគង្វាល ឬចូលរួមក្នុងកម្មវិធីញាំបង្អែម ដែលធ្វើ៣ខែម្តង។ ការញាំបង្អែមនេះ គឺសំរាប់ផ្តោតលើក្រុមតូច ហើយអ្នកដឹកនាំក្រុមតូចមួយចំនួនជាអ្នករៀបចំកម្មវិធីនេះដើម្បីគេអាចណែនាំកម្មវិធីដែលគេដឹកនាំ។

ក្រុមតូចគឺជាផ្នែកសំខាន់ក្នុងប្រពន្ធបង្កើតសិស្ស នៃ BUMC។ អ្នកដឹកនាំក្រុមជំនុំបង្ហាញថាក្រុម តូចគឺជាគោលតំលៃស្នូល ហើយរើសបុគគលិកដែលមានទស្សនៈដូចគ្នា។ សមាជិកបានឆ្លើយតបដោយការបំរើជាអ្នកដឹកនាំ ហើយចូលរួមក្នុងក្រុមតូច។ ក្រុមជំនុំBUMC បានប្រែក្លាយពី ក្រុមជំនុំដែលមានក្រុមតូច ទៅជាក្រុមជំនុំនៃក្រុមតូច។ លទ្ធផលដែលទទួលបាន គឺជាបរិស្ថាននៃសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក ដែលសមាជិករីកចំរើនក្នុងព្រះគ្រីស្ទ ហើយស្គាល់ និងថៃរក្សាគ្នាទៅវិញទៅមក។

Rev. Thomas Cross, គ្រូគង្វាលបង្កើតសិស្ស

# ការបង្កើតសិស្សដោយចេតនា តាមតំបន់

## សន្និបាទប្រចាំឆ្នាំរដ្ឋ Oklahoma

សន្និបាទប្រចាំឆ្នាំរដ្ឋ Oklahoma កំពុងតែផ្តោតការខំប្រឹងប្រែងលើប្រព័ន្ធបង្កើតសិស្សដោយចេតនា និងជាវិថីសំរាប់គ្រប់ក្រុមជំនុំ។ ប្រធានតំបន់ (ប្រធានផ្នែកយុត្តិសាស្រ្តបេសកកម្ម) កំពុងតែជួយក្រុមជំនុំនិមួយៗក្នុងការបង្កើតឪកាសសំរាប់ក្រុមជំនុំទាំងអស់អាចក្លាយជាអ្នកដើរតាមព្រះគ្រីស្ទ ដោយស្មោះត្រង់។ កាលពីដើមវគ្គបួនឆ្នាំ (Quadrennium) ក្រុមព័ន្ធកិច្ចបង្កើតសិស្សនៃសន្និបាទយើង ជួបជាមួយលោក Jeff Campbell ដែលជាអ្នកធ្វើការនៅ Discipleship Ministries ដើម្បីជួយឲ្យពួកយើងយល់ពីគោលការណ៍នៃប្រព័ន្ធបង្កើតសិស្សដោយចេតនា។ បុគ្គលិកក្នុងសន្និបាទ បង្រៀនសិក្ខាសាលាស្រដៀងគ្នានេះ ដល់ក្រុមជំនុំក្នុងតំបន់។ ក្រុមជំនុំតូចៗ ឬក្រុមជំនុំដាច់ស្រយាលទទួលបានការហ្វឹកហ្វឺន ដែលផ្តោតលើ H.O.P.E. ដែលជាប្រព័ន្ធបង្កើតសិស្ស ផ្អែកលើ កថាខណ្ឌ័១២២ នៃសៀវភៅវិន័យ។ H.O.P.E តំណាងឲ្យ Hospitality (បដិសណ្ឋារកិច្ច) Offering Christ (ចែកចាយពីព្រះគ្រីស្ទ) Purpose (គោលបំណង) និង Engagement (ការទាក់ទង)។ ក្នុងឆ្នាំនេះ ក្នុងរដូវមហាសន្និបាទ យើងនឹងផ្តល់កិត្តយសដល់ក្រុមជំនុំមួយក្នុងតំបន់និមួយៗ នូវពាន One Matters Discipleship Award ជាការទទួលស្គាល់ចំពោះការរីកធំធាត់របស់ក្រុមជំនុំតាមរយៈការថ្វាយខ្លួន និងការជ្រមុជទឹក។ ផែនការអនាគតមានដូចជាការជួយក្រុមជំនុំក្នុងតំបន់ ពេលដែលគេកំពុងរៀបចំផ្លូវច្បាស់លាស់ នៃការបង្កើតសិស្ស និងផែនការនៃការបង្កើតសិស្ស ដើម្បីផ្លាស់ប្តូរពិភពលោក។ ដូចជាសារក្យប៉ុលសរសេក្នុងសំបុត្រទីមួយរបស់គាត់ទៅកាន់ប្រជាជនក្នុងទីក្រុងកូរិនថូស «ប៉ុន្តែខ្ញុំនឹងនៅក្នុងទីក្រុងអេភេសូរ រហូតដល់ថ្ងៃទី៥0 ដោយសារទ្វារដ៏ទូរលាយ ហើយស្រួលបានបើកចំហរឲ្យខ្ញុំ ហើយក៏មានពួកឃាត់ឃាំងជាច្រើនដែរ។» ក្រុមជំនុំពិតជានឹងជួបការឃាត់ឃាំង ក្នុងពិភពលោក តែក៏មានទ្វារបើកទូរលាយ និងពន្ធកិច្ចល្អ សំរាប់យើងរាល់ថ្ងៃដែរ។ ប្រពន្ធ័បង្កើតសិស្សដោយចេតនា ជួយអ្នកដើរតាមព្រះគ្រីស្ទ ឲ្យដឹកនាំអ្នកដទៃទៀតចូលតាមទ្វារទាំងនោះមកកាន់ព្រះបាទរបស់ព្រះយេស៊ូវ។

Rev. Derrek Belase, នាយកនៃការបង្កើតសិស្ស

# ប្រព័ន្ធបង្កើតសិស្សដោយចេតនា៖ ឧទាហរណ៍ ក្នុងក្រុមជំនុំមួយ

## ក្រុមជំនុំសន្តិភាព United Methodist Church, Pickerington, Ohio

វិធីបង្កើតសិស្សរបស់ ក្រុមជំនុំសន្តិភាព គឺផ្តោតទៅលើការផ្លាស់ប្តូរមនុស្សឲ្យទៅជាអ្នកដែល ដើរតាមព្រះគ្រីស្ទ ស្រឡាញ់ព្រះ និងអ្នកដទៃ។ យើងជួបមនុស្សក្នុងសហគមន៍របស់យើង ក្នុងស្ថានភាពអារម្មណ៍ និងសេចក្តីត្រូវការចេញពីចិត្ត របស់គេ ដោយចែកចាយពីព្រះគុណដំបូងរបស់ព្រះ តាមរយៈក្រុមតូច ការបំរើ និងទីបន្ទាល់ និងឪកាសបេសកកម្ម និងការឈោងចាប់។ កម្មវិធីដូចជាការចូលរួមរំលែកទុក្ខ ការថែរទាំអ្នកលេងលះគ្នា អ្នកលេងបាល់ទាត់ ក្មេងមតេយ្យ និងបំរើសហគមន៍របស់យើងដោយការស្ម័គ្រចិត្តក្នុងកម្មវិធីរបស់ទីក្រុង លាបថ្នាំអាគារសាលារៀន ។ល។ ការទាំងនេះជួយឲ្យយើងបង្ហាញសេចក្តីស្រឡាញ់ដល់មនុស្សយ៉ាងច្បាស់។

ពេលយើងសាងទំនាក់ទំនងជាមួយអ្នកដទៃ យើងអញ្ជើញគេមកចូលរួមកម្មវិធីថ្វាយបង្គំ ក្រុមតូច និងក្រុមព័ន្ធកិច្ច។ យើងរំពឹងទុកថា អ្នកដែលត្រូវបានអញ្ជើញមកក្រុមជំនុំសន្តិភាព នឹងចូលរួមក្នុងសកម្មភាពក្នុងក្រុមជំនុំ។ ការចូលរួម និងជួយឲ្យគេទទួលបានបទពិសោធន៍នៃព្រះគុណនៃការរាប់ជាសុច្ចរិត ដែលធ្វើការក្នុងចិត្ត សេចក្តីជំនឿ និងអត្តចរិតរបស់គេ។

ពេលដែលមនុស្សរីកចំរើន គេនឹងចង់ឲ្យសេចក្តីជំនឿរបស់គេរីកចំរើនដែរ។ ការបង្កើតសិស្សស៊ីជំរៅ នឹងត្រូវផ្តល់ឲ្យតាមក្រុមសន្យា ដៃគូរមួយទល់និងមួយ និងការហ្វឹកហ្វឺនផ្នែកដឹកនាំ ផ្សេងៗទៀត។ តាមរយៈព័ន្ធកិច្ចទាំងនេះ និងការសន្ទនាផ្នែកព្រលឹងវិញ្ញាណនេះហើយ ដែលក្រុមជំនុំអាចជួយឲ្យមនុស្សទទួលបានព្រះគុណនៃការរាប់ជាសុច្ចរិតរបស់ព្រះ ដែលជួយឲ្យគេមិនធ្វើតាមសាច់ឈាម តែរីកចំរើនក្នុងសេចក្តីស្រឡាញ់។ ក្រុមជំនុំសន្តិភាពផ្តោតលើការឆ្លើយតបចំពោះឆន្ទៈ គោលបំណង និងអត្តចរិករបស់មនុស្សម្នាក់ៗ។

បន្ទាប់ពីលះបង់បីបួនឆ្នាំរួចមក មនុស្សមួយចំនួននឹងចាប់ផ្តើមទទួលបានបទពិសោធន៍ នៃការញែកជាបរិសុទ្ធរបស់ព្រះ។ បទពិសោធន៍នេះ គឺជាការរស់នៅក្នុងរូបកាយនៃព្រះគ្រីស្ទ ហើយមានឥទ្ធិពលល្អណាស់ ចំពោះព្រលឹងវិញ្ញាណរបស់មនុស្សម្នាក់ៗ។ អ្នកទាំងនោះកំពុងត្រូវបាន សំអាតក្នុងសេចក្តីស្រឡាញ់ ការធ្វើការល្អ និងការយល់យ៉ាងស៊ីជំរៅ ពីការដើរតាមព្រះយេស៊ូវ ស្រឡាញ់ព្រះអស់ពីចិត្ត វិញ្ញាណ គំនិត និងកំឡាំង និងស្រឡាញ់អ្នកដទៃ ដូចជាគេស្រឡាញ់ខ្លួនឯងដែរ។ ក៏មានការអនុវត្តន៍ផ្នែកព្រលឹងវិញ្ញាណចំនួន៦ទៀត ដែលយើងចង់ឲ្យគេធ្វើទោះបីគេនៅកំរិតណាក៏ដោយ។ ៣ដំបូង នឹងជួយឲ្យគេស្រឡាញ់ព្រះថែមទៀត

(ការថ្វាយបង្គំផ្ទាល់ខ្លួន ការថ្វាយបង្គំរួមគ្នា និងការដាក់ដង្វាយ) ហើយ៣បន្ទាប់ជួយឲ្យគេស្រឡាញ់អ្នកដទៃ (បំរើ/ទីបន្ទាល់ សាងទំនាក់ទំនង និងការរីកចំរើនផ្ទាល់ខ្លួន) ។ ការអនុវត្តន៍ផ្នែកព្រលឹងវិញ្ញាណ នឹងជួយឲ្យមនុស្សរស់នៅដោយចិត្តឆេះឆួល ហើយហើយមនុស្សគ្រប់កំរិតអាចអនុវត្តន៍ការទាំង៦នេះ។ ការអនុវត្តន៍ទាំងនេះ និងកម្មវិធីបង្កើតសិស្សដោយចេតនា ត្រូវបានរចនាឡើងដើម្បីឲ្យមនុស្សអភិវឌ្ឍន៍សេចក្ដីជំនឿរបស់គេ។

សំរាប់ពត៌មានបន្ថែម អំពីយន្តការនេះ សូមទាក់ទង Peace Church 614-837-3732 or scottd@peaceumc.org យើងខ្ញុំនឹងរីករាយក្នុងការពន្យល់បន្ថែមយ៉ាងលំអិត។

Rev. Bill Lyle, Senior Pastor

# ការបង្កើតសិស្សដោយចេតនាក្នុងសេចក្ដីអធិប្បាយជាសេរី/ធនធានក្រុមជំនុំទាំងមូល

## មហាសន្និបាទប្រចាំឆ្នាំ រដ្ឋ South Carolina

តើយើងជួយឲ្យក្រុមជំនុំគិតពីការបង្កើតសិស្សជាជាងការរកសមាជិកដោយរបៀបណា? តើពេលណា និងកន្លែងណា ដែលយើងនិយាយពីការផ្លាស់ពីសមាជិកទៅជាសិស្ស? គ្រូគង្វាលនៅ South Carolina មួយចំនួនពិភាក្សាគ្នាពីសំនួរទាំងនេះ នៅ Intentional Growth Center នៅ Lake Junaluska។ ការពិភាក្សានេះ ផ្អែកលើសៀវភៅរបស់លោក Phil Maynard's ដែលមានចំណងជើងថា Shift ដើម្បីអាចជួយឲ្យគ្រូគង្វាលយូណៃធីតមេថូឌីស្ទផ្សេងទៀតគិតពីការនេះដែរ។ បន្ទាប់ពីមានការសន្ទនាជាមួយគ្នាយ៉ាងច្រើន ក្រុមនេះឲ្យនិយមន័យពាក្យ «ការបង្កើតសិស្ស» ថា «ការឆ្លើយតបចំពោះសេចក្ដីអញ្ជើញរបស់ព្រះយេស៊ូវ «ចូរមកតាមខ្ញុំ» »។ ចាប់ពីពេលនោះមក យើងចាប់ផ្ដើមបង្កើតសេចក្ដីអធិប្បាយជាសេរី និងធនធានសំរាប់ក្រុមជំនុំទាំងមូល ដោយប្រើចំណងជើងនេះ។

ក្រុមជំនុំនិមួយៗមាន«សមាជិក» ដែលមានកំរិតនៃសេចក្ដីជំនឿផ្សេងៗគ្នា។ កិច្ចការរបស់ក្រុមជំនុំគឺត្រូវឈោងចាប់មនុស្សដែលកំពុងស្វែងរកព្រះ ហើយក្នុងពេលជាមួយគ្នានោះដែរ ក៏ជួយឲ្យគ្រប់គ្នាមានទំនាក់ទំនងជាមួយព្រះកាន់តែជិតស្និទ្ធ។ ក្នុងអត្ថបទដែលមានចំណងជើងថា «មក តាមខ្ញុំ» យើងសង្ឃឹមថាវានឹងអាចជួយឲ្យគ្រប់គ្នានិយាយពីការផ្លាស់ពីសមាជិកភាព ទៅជាសិស្ស។ យើងសង្ឃឹមថា ក្រុមជំនុំនឹងរៀនបានពីការបង្កើតសិស្ស របស់លោកពេត្រុស ដែលជំរុញឲ្យពួកគេចង់ចាប់ផ្ដើមដំណើរជីវិតរបស់ពួកគេជាសិស្សរបស់ព្រះយេស៊ូវ។

ចំនុចចាប់ផ្ដើមនៃគំរោងនេះគឺមានសេចក្ដីអធិប្បាយចំនួន ៧ ដែលផ្អែកលើដំណើរជីវិតរបស់ លោកពេត្រុសដែលជាសិស្ស។ យើងមានរឿងប្រវត្តិរបស់គាត់ សេចក្ដីអធិប្បាយ វីដេអូ និងធនធានផ្សេងទៀត។ យើងសង្ឃឹមថា គ្រូគង្វាលនឹងប្រើសេចក្ដីអធិប្បាយទាំងនេះជាគំរូ សំរាប់ផ្លាស់ពីសមាជិក ទៅជាសិស្ស។

យើងនឹងផ្ដល់ជូននៅធនធានផ្សេងទៀតសំរាប់ក្រុមជំនុំទាំងអស់។ ក្រុមអ្នកសរសេរក៏គិតពីភាសាសំរាប់គ្រប់វ័យ ដូចជាកុមារ យុវជន និងមនុស្សពេញវ័យ។ គ្រប់ទាំងធនធានទាំងអស់មានជា PDF ដែលអាចរកបានក្នុងគេហទំព័ររបស់ មហាសន្និបាទប្រចាំឆ្នាំ រដ្ឋ South Carolina

អ្នកនិពន្ធរួមមាន Ross Chellis, Brad Gray, Angela Ford Nelson, Ken Nelson, Paul Harmon, Wendy Hudson-Jacoby, and Neal Woods. Jim

Arant, Cathy Joens, ហើយ Chris Lynch ជាអ្នកដឹកនាំក្រុមគំរិតអាយុ។ George Donigian, ដែលធ្លាប់កែសម្រួលសៀវភៅកូនក្មេង គឺជាអ្នកកែសម្រួលសំរាប់គំរោងនេះ។

ខគម្ពីរ និងចំណងជើង៖
ការដើមតាម - ម៉ាកុស ១៖១៦-២០
ការសារភាពបាប - ម៉ាថាយ ១៦៖១៣-២០
ភាពស្មោក់ស្មើរ - លូកា ២២៖៥៤-៦២
ការផ្លាស់ប្រែ -យ៉ូហាន ២១៖១-១៤
ការបំរើ - យ៉ូហាន ២១៖១៥-១៩
ការប្រកាស - កិច្ចការ ២៖២៩-៣៩
ការឆ្លងកាត់ - កិច្ចការ ១០៖៣៤-៣៨

Rev. George Hovaness Donigian, Development Editor (on behalf of the Discipleship Curriculum Team)

# ការបង្កើតសិស្សដោយចេតនា៖ ប្រព័ន្ធដែលមហាសន្និបាតស្នើរ

## មហាសន្និបាទប្រចាំឆ្នាំ Western Pennsylvania

គ្រប់ការចាប់ផ្តើមរបស់ដំណើរទាំងអស់ យើងត្រូវបោះជំហានដំបូង។ ជួនកាលយើងដឹងកន្លែង ដែលយើងចង់ទៅ ហើយជំហានដំបូងនោះជាអ្នកកំណត់ទិសដៅ។ តែពេលដែលយើងមិនដឹង នោះយើងនឹងមិនដឹងថា ត្រូវបោះជើងទៅណាទេ។ បើសំណាង នោះនឹងមានសេចក្តីណែនាំ មួយមកបង្ហាញផ្លូវ។

ដំណើរជីវិតសំខាន់មួយ គឺជាដំណើរជាមួយព្រះយេស៊ូវ តែដូចជាដំណើរជីវិតផ្សេងទៀតដែរ វាអាចសាំញ៉ាំណាស់។ យើងជាក្រុមជំនុំ អាចសង្ឃឹមចង់បានការល្អបំផុត ឬ យើងអាចជួយបង្ហាញផ្លូវ។ យើងអាចផ្តល់ជាឱកាសល្អៗ ដែលនឹងអាចបំពេញសេចក្តីត្រូវការនិងចំណង់ចិត្តឬយើងអាចដឹកនាំអ្នកទាំងនោះទៅកាន់សេចក្តីស្កប់ចិត្តយ៉ាងពិត ហើយរីកចំរើន។

ផ្លូវទៅកាន់ការបង្កើតសិស្ស គឺជាគោលបំណងចេតនា ដែលជួយឲ្យក្រុមជំនុំបង្កើតប្រព័ន្ធនៃការ ស្វាគមន៍ ការករសាង និងការបង្កើតសិស្សស៊ីជំរៅ។ វាផ្តោតលើការយល់តាមបែបលោកវេស្លីដែលថា ការបង្កើតសិស្ស គឺជាដំណើរនៃព្រះគុណ និងយល់ថា ការបង្កើតសិស្ស គឺជាពន្ធ័កិច្ចគ្រប់ជ្រុងជ្រោយ ដែលជាយន្តការនៃផ្នែកបួនដែលមានសារៈសំខាន់ស្មើរៗគ្នា៖

សហគមន៍ (Koinonia), ការបង្រៀន/ការរៀន (didache), ការប្រកាស/ការផ្លាស់ប្រែ (kerygma) និងការបំរើ (diakonia)។ ពេលដែលយើងគូសផែនទីនៃដំណើរនេះ យើងជួយចង្អុលបង្ហាញ អ្នកដទៃទៅកាន់ទិសដៅត្រឹមត្រូវនៃការបង្កើតសិស្ស។

Rev. Chris Kindle, Director of Discipleship and Spiritual Formation

# ក្ការបង្កើតសិស្សដោយចេតនា៖ ការដឹកនាំពីមហាសន្និបាទ

### មហាសន្និបាទ Upper New York

ក្នុងមហាសន្និបាទ Upper New York ប្រពន្ធ័ការបង្កើតសិស្សដោយចេតនា ត្រូវបានចាត់ទុកជាផ្នែកមួយយ៉ាងសំខាន់សំរាប់ក្រុមជំនុំទាំងអស់។ ដូច្នេះ មានវិធីជាច្រើនដែលត្រូវបានប្រើជាមួយក្រុមជំនុំ ដើម្បីបង្កើតប្រពន្ធ័នៃការបង្កើតសិស្ស។ មានការខំប្រឹងប្រែងមួយចំនួនដើម្បីបង្ហាញពីគុណតំលៃនៃប្រពន្ធ័នៃការបង្កើតសិស្សដោយចេតនា និងសារៈសំខាន់នៃបេសកកម្ម និងពន្ធ័កិច្ចរបស់ក្រុមជំនុំ។ ការនេះត្រូវបានបង្ហាញចេញពីលោកអភិបាលប្រធានតំបន់និងបុគ្គលិក។ជាងនេះទៀតពត៌មានទាំងប៉ុន្មាន តែមានបញ្ចូលរឿង និងដំណឹងអំពីប្រពន្ធ័ការបង្កើតសិស្សដោយចេតនា។

ពេលដែលគុណតំលៃ និងសារៈប្រយោជន៍ ត្រូវបានចែកចាយ ឪកាសនៃកម្មវិធីត្រូវបានផ្តល់កំរិតមហាសន្និបាទ។គោលបំណងនៃកម្មវិធីមិនមែនចង់ផ្តល់ប្រពន្ធ័មួយឲ្យក្រុមជំនុំធ្វើតាមទេ តែវាជាការបង្រៀនអំពីផ្នែកនៃប្រពន្ធ័បង្កើតសិស្សដែលមានសុពលភាព។ ហើយក៏មានការ ថៃទាំឲ្យប្រពន្ធ័នេះដើរតាមគន្លងនៃទេវវិទ្យាតាមបែលោកវេស្លី។ តំបន់និមួយៗក៏មានការបង្រៀនបែបសិក្ខាសាលា ហើយក៏មានការបង្រៀនក្នុងមហាសន្និបាទទាំងមូល។ក្នុងវគ្គមួយដែលមានចំណងជើងថាដៃព្យួរាស់ (Hand to Plow) ក្រុមជំនុំត្រូវបានផ្តល់ឪកាស ដើម្បីមើលឲ្យបានស៊ីជម្រៅ ថាវាទាមទារអ្វីខ្លះក្នុងការបង្កើតសិស្សនិងថាតើត្រូវធ្វើយ៉ាងម៉េចដើម្បីបង្កើតប្រពន្ធ័សំរាប់ក្រុមជំនុំ។

ក្រុមជំនុំត្រូវបានលើកទឹកចិត្តឲ្យអានសៀវភៅដែលមានប្រពន្ធ័នៃការបង្កើតសិស្ស។ ផ្នែកមួយនៃការរៀនគឺដើម្បីស្វែងរកប្រព័ន្ធនៃការបង្កើតសិស្សដែលមានសុពលភាព។ ផ្នែកទាំងនោះគឺទាក់ទងទៅនិងកំរិតនៃការរីកចំរើនសំរាប់អ្នកដើរតាមព្រះយេស៊ូវ។ ក្រុមជំនុំត្រូវតែផ្តល់ឪកាសរីកចំរើនសំរាប់អ្នកដែលស្វែងរកព្រះគ្រីស្ទ។ ទីពីរ ក្រុមជំនុំត្រូវតែផ្តល់ឪកាសសំរាប់អ្នកដែលបានសំរេចចិត្តដើរតាមព្រះគ្រីស្ទឬអ្នកដែលទើបមានជំនឿថ្មី។ ទីបី ក្រុមជំនុំត្រូវតែផ្តល់ឪកាសសំរាប់អ្នកដែលមានជំនឿរឹងមាំជាមួយព្រះគ្រីស្ទ ក៏ដូចជាអ្នកដែលមានជំនឿយូរមកហើយ។ អ្នកដែលមានជំនឿយូរជាអ្នកដឹកនាំអ្នកដែលទើបតែជឿ។ចំនុចទាំងនេះស៊ីជាមួយរលកនៃព្រះគុណដែលមានក្នុងទេវវិទ្យារបស់លោកវេស្លី៖ ព្រះគុណដំបូង ព្រះគុណរាប់ជាសុច្ចរិត ព្រះគុណញែកជាបរិសុទ្ធ និងសំរាប់អ្នកដែលខំសំដៅទៅរកជីវិតល្អឥតខ្ចោះ។

កម្មវិធីលំអិត មិនត្រូវបានបង្រៀនទេ ព្រោះក្រុមជំនុំត្រូវបង្កើតកម្មវិធីទៅតាមបរិបទក្រុមជំនុំរៀងៗខ្លួន។ យើងអាចផ្តល់ជាយោបល់ខ្លះៗ តែក្រុមជំនុំនិមួយត្រូវបង្កើត

កម្មវិធីសំរាប់សមាជិក និងសហគមន៍រាងៗខ្លួន។ យើងនឹងបង្ហាញរូបភាពមួយចំនួនសំរាប់ក្រុមជំនុំអាចពិចារណា។ យើងសង្ឃឹមថា រូបភាពនោះនឹងជួយឲ្យក្រុមជំនុំបង្កើតជាប្រពន្ធ័ដែលមានដំណើរការ និងស្របតាមរលកនៃព្រះគុណ តាមបែបលោកវេស្លី។

Rev. Dr. Aaron M. Bouwens, Director of Vital Congregations

# ការបង្កើតសិស្សដោយចេតនា៖ អន្តរជាតិ

**Manila Episcopal Area**

The UMC DOC (United Methodist Church, Disciples of Christ) គឺជាកម្មវិធីពិសេសបង្កើតឡើងសំរាប់ជាគំរូនៃការបង្កើតសិស្ស សំរាប់ជួយគ្រូគង្វាល ចាស់ទុំ និងសមាជិក ក្រុមជំនុំ ក្នុងតំបន់ Manila Episcopal Area ដែលមានមហាសន្និបាទប្រចាំឆ្នាំ១២ និងដំបន់២៨។

ក្នុងប្រព័ន្ធDOC សិស្សចូលរួមក្នុងការផ្សាយដំណឹងល្អ បង្កើតសិស្ស និងក្រុមថែទាំ។ ពួកសិស្ស ចែកចាយពីសេចក្ដីជំនឿរបស់គេ អញ្ជើញអ្នកដទៃឲ្យចូលក្នុងជីវិតជាមួយព្រះគ្រីស្ទ។ ពេលអ្នកណាម្នាក់ទទួលព្រះគ្រីស្ទ ជាព្រះសង្គ្រោះ នោះគេនឹងត្រូវអញ្ជើញឲ្យចូលរួមក្នុងក្រុមថែទាំ។ ក្នុងក្រុមទាំងនេះ ពួកសិស្សថ្មី នឹងទទួលបានការស្រឡាញ់ ការអភិវឌ្ឍន៍អតចរិកឲ្យដូចព្រះគ្រីស្ទ ទទួលបានការហ្វឹកហ្វឺន និងការប្រកបជាមួយពួកសិស្សឯទៀត។ ហើយពួកសិស្សទាំងនោះ នឹងរៀនពីការបង្កើតសិស្ស។

គំរូនៃប្រព័ន្ធនេះមាន៖ ការផ្សាយដំណឹងល្អ (មួយទល់មួយ តាមផ្ទះ ក្រុមថែទាំ, ការជួបជុំគ្នា និងការថ្វាយបង្គំ) ការបើកសំដែង (ការជួបគ្នាមួយអាទិត្យម្ដង, ការថ្វាយបង្គំខ្លីរាល់ថ្ងៃ, ដៃគូរអធិស្ឋាន, សិក្ខាសាលានៃបទពិសោធន៍ពីមុន, ការសំរាកកំសាន្តបីថ្ងៃ, សិក្ខាសាលានៃបទពិសោធន៍បន្ទាប់, ថ្នាក់ទី១នៃគណនេយ្យភាពនៃការបង្កើតសិស្ស) ហ្វឹកហ្វឺន (ថ្នាក់ទី២, ៣, ៤នៃគណនេយ្យភាពនៃការបង្កើតសិស្ស) ការផ្ដល់អំណាច (ចាត់តាំងអ្នកដឹកនាំក្រុមថែទាំ, ថ្នាក់ទី ៥, ៦ នៃគណនេយ្យភាពនៃការបង្កើតសិស្ស)

គំរូរបស់ UMC DOC មានជាឧទាហរណ៍ និងសេចក្ដីណែនាំ ពីការថ្វាយបង្គំប្រចាំថ្ងៃ និងការសរសេរកំណត់ហេតុប្រចាំថ្ងៃ, ការប្រជុំក្រុមថែទាំរាល់អាទិត្យ, ការប្រជុំបណ្ដាញក្រុមថែទាំប្រចាំអាទិត្យ, ថ្នាក់បេះដូងកក់ក្ដៅ UMC និងការសំរាកកំសាន្ត, ថ្នាក់គណនេយ្យភាពនៃការបង្កើតសិស្ស, ថ្នាក់សមាជិកភាពសំរាប់អ្នកជឿថ្មី និងថ្នាក់ពន្ធ័កិច្ចនៃការបំរើ។

ដើម្បីបានឃើញគំរូទាំងមូល សូមមើលក្នុង៖ UMCdiscipleship.org/UMCDOC

Rev. Magusig 'John' B. Manalo, Jr., Director for Connectional Ministries, UMC DOC (Disciples of Christ), Manila Episcopal Area of the Philippines Central Conference

«យើងមិនអាចប
ង្កើតសិស្សដោយ
គ្មានទំនាក់ទំនង
ជាមួយមនុស្ស
បានទេ។»

# ការសិក្សាបន្ថែម

*Start with Why: How Great Leaders Inspire Everyone to Take Action.* Simon Sinek. Portfolio, 2011.

*Building a Discipleship Culture.* Mike Breen. 3dm Publishing, 2014.

*Shift: Helping Congregations Back Into the Game of Effective Ministry.* Phil Maynard. Self published, 2013.

*Membership to Discipleship: Growing Mature Disciples Who Make Disciples.* Phil Maynard. Excellence in Ministry Coaching, 2016.

*A Disciple's Path Daily Workbook: Deepening Your Relationship with Christ and the Church.* James Harnish with Justin LaRosa. Abingdon Press, 2012.

Michael Jr., *Know Your Why:* www.youtube.com/watch?v=LZe5y2D60YU

Simon Sinek, *Start with Why: Ted Talk:* www.ted.com/talks/simon_sinek_how_great_leaders_inspire_action

«យើងគួរឈប់ផ្តោតលើការ «ជួសជុល» ក្រុមជំនុំ ទៅជាការបង្កើត និងបណ្តុះបណ្តាលសិស្ស»

# អំពីអ្នកនិពន្ធ



លោកគ្រូគង្វាល Junius B. Dotson គឺជាអគ្គលេខាធិការនៃ Discipleship Ministires ដែលជាភ្នាក់ងារអន្តរជាតិមួយនៃក្រុមជំនុំយូណៃធីតមេថូឌីស្ទ។ គាត់ចាប់ផ្តើមការងារនេះនៅថ្ងៃ១ ខែ៧ ឆ្នាំ២០១៦។ មុនពេលគាត់មកកាន់ដំណែងនេះ គាត់គឺជាគ្រូគង្វាលរាមច្បងក្នុងក្រុមជំនុំ Saint Mark United Methodist Church in Wichita, Kansas, ដែលគាត់ជាអ្នកជួយឲ្យមានសមាជិក៣៥០០នាក់ មានកន្លែងថ្វាយបង្គំជាច្រើន។ ក្រុមជំនុំនេះក៏ទទួល E.C. Tyree Health & Dental Clinic ដែលផ្តល់ការថែរទាំសុខភាពក្នុងតំលៃថោកដល់អ្នកជំងឺជាច្រើនពាន់នាក់ជារាងរាល់ឆ្នាំ។

លោកគ្រូ Dotson មានសញ្ញាបត្រ័ខាងវិទ្យាសាស្រ្តនយោបាយ ដែលផ្តោតលើសេដ្ឋកិច្ច នៅមហាវិទ្យាល័យ University of Texas at Arlington. ពេលគាត់នៅរៀន គាត់គឺជាប្រធាន Alpha Phi Alpha, the nation’s oldest African-American fraternity.

លោកគ្រូ Dotson រៀនថ្នាក់អនុបណ្ឌិតនៅ Perkins School of Theology at Southern Methodist University in Dallas, Texas, ហើយទទួលបានសញ្ញាបត្រ័ Master of Divinity degree from the Pacific School of Religion in Berkeley, California. គាត់ទទួលបានប្រេងតាំងក្នុងខែមិថុនា ឆ្នាំ១៩៩២។ ក្នុងឆ្នាំ១៩៩៦ លោកគ្រូ Dotson បាងបង្កើតក្រុមជំនុំថ្មីមួយ ឈ្មោះ Genesis United Methodist Church, ក្នុងតំបន់ Silicon Valley of California, ហើយក្រុមជំនុំនេះរីកចំរើនជាក្រុមជំនុំចំរុះជាតិសាស្រ្ត ដែលមានគ្នាចំនួន៥០០នាក់។

ជាអ្នកដឹកនាំម្នាក់ដែលឆ្លើយតបចំពោះឱកាសថ្មីៗ ដោយការឆ្នៃប្រឌិតខ្ពស់ លោកគ្រូ Dotson ជឿថាពន្ធ័កិច្ចដែលមានសុពលភាព គឺមានការហ្វឹកហ្វឺន ការអភិវឌ្ឍន៍ និងពង្រឹងអ្នកដឹកនាំ ឲ្យបង្កើតពន្ធ័កិច្ចដែលឆ្លើយតបសេចក្តីត្រូវការរបស់មនុស្ស ទាំងរូបកាយ ប្រាជ្ញា និងវិញ្ញាណ។

លោកគ្រូ Dotson មានការផ្ទៃប្រឌិតខ្ពស់ ដែលទាក់ទាញចំណាប់អារម្មណ៍ជាច្រើន ។ ពន្ធ័កិច្ចរបស់គាត់ត្រូវបានចេញផ្សាយក្នុង San Jose Mercury News, The San Francisco Examiner, The Sacramento Bee, The Wichita Eagle, religious journals and segments on CBS Radio’s “The Osgood File,” as well as on ABC, NBC and CBS affiliates in San Francisco, San Jose and Wichita.

លោកគ្រូ Dotson ជាគ្រូអធិប្បាយ និងអ្នកនិយាយសាធារណៈដ៏ពូកែ ហើយគេទទួលស្គាល់ភាព ពូកែខាងបង្កើតទំនាក់ទំនង ដើម្បីធ្វើការឲ្យបានសំរេច ក្នុងក្រុមជំនុំ ក៏ដូចជាក្នុងសហគមន៍។ លោកគ្រូបំរើក្នុង Board of Ordained Ministry and the Revitalization Taskforce of the Kansas West Conference (ឥឡូវស្ថិតនៅក្នុង Great Plains Conference) គាត់ក៏បានបំរើក្នុង Fitzgerald Program, ដែលជាកម្មវិធីរបស់ Discipleship Ministries ដើម្បីហ្វឹកហ្វឺនគ្រូគង្វាលក្នុងចាប់ផ្តើមក្រុមជំនុំថ្មី។ ពីឆ្នាំ ២០០៩ ដល់ ២០១២ លោកគ្រូ Dotson បំរើជាគណៈកម្មការនាយករបស់ Discipleship Ministries, ដែលគាត់ជាប្រធាន ផ្នែក New Church Start/Parth 1។ គាត់ក៏បំរើក្នុងគណៈកម្មការនាយករបស់ Wichita Food Bank Executive Board, Wichita Chldren’s Home Board, W. G. Williams Community Foundation Board. Wichita Ministerial Alliance និងត្រូវបានចៅហ្វាយក្រុង Kansas តែងតាំងជាប្រធានក្នុង Kansas Sentencing Commission.

លោកគ្រូ Dotson រស់នៅទីក្រុង Nashville, Tennessee, ហើយរៀបការជាមួយ Christina Price. គេមានកូនពីរនាក់ឈ្មោះ Wesley និង Janelle.







# យើងមិនអាចបង្កើតសិស្សដោយគ្មានទំនាក់ទំនងជាមួយមនុស្សបានទេ។

យើងមិនអាចបង្កើតកម្មវិធីធ្វើឲ្យក្រុមជំនុំយើងមានភាពរីកចំរើនទេ។ វាត្រូវការចលនានៃការបង្កើតសិស្ស ហើយចាប់ផ្តើមយន្តការបង្កើតសិស្សដលៃ់ឈាងចាប់ដល់សហគមន៍។



យើងអញ្ជើញអ្នកឲ្យប្រើធនធានដើម្បីចាប់ផ្តើមការសន្ទនាក្នុងបរិបទពន្ធកិច្ចរបស់អ្នក អំពីការបង្កើតបែបផែននៃជីវិតនៃការបង្កើតសិស្សដោយចេតនា។

សូមអញ្ជើញទៅកាន់ **#SeeAllThePeople**



DISCIPLESHIP MINISTRIES
The United Methodist Church

COM971











